ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១១ លេខ ១ | មករា - មីនា ឆ្នាំ២០០៧ | តម្លៃ ១.៥០០៛

## បញ្ហាប្រឈមនៃការគ្រប់គ្រងធនធានទឹកនៅកម្ពុជា

**បណ្ឌិត ធន់ វឌ្ឍនា និង លោក ចែម ផល្លា ពិភាក្សារំលែកពីប្រធានបទចំបងៗមួយចំនួនទាក់ទិននឹងការគ្រប់គ្រងទឹកនៅកម្ពុជា នៅក្នុងសិក្ខាសាលា WRMRCDP នាពេលថ្មីៗ***

យោងតាមទីតាំងភូមិសាស្ត្រ និងរបបទឹកភ្លៀងតំបន់ត្រូពិច ប្រទេសកម្ពុជា មានប្រភពទឹកយ៉ាងសំបូរ សំរាប់បំរើការដឹកជញ្ជូន ឧស្សាហកម្ម កសិកម្ម វារីវប្បកម្ម និងគោលដៅប្រើប្រាស់ក្នុងស្រុកផ្សេងៗទៀត ។ ទោះជាយ៉ាងនេះក្តី មានបញ្ហាខ្វល់ខ្វាយមួយចំនួនទាក់ទិននឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹក សំរាប់ជំរុញផលិតកម្មកសិកម្ម និងកាត់បន្ថយភាពក្រីក្រ ។ កសិកម្ម គឺជាផ្នែកមួយដ៏សំខាន់ជួយរួមចំណែកកាត់បន្ថយភាពក្រីក្រ ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-១០ (NSDP) របស់រាជរដ្ឋាភិបាល ។ ប្រព័ន្ធធារាសាស្ត្រ



*វាលស្រែមានប្រព័ន្ធស្រោចស្រពនៅត្រពាំងត្របែកក្នុងខេត្តកំពង់ឆ្នាំង*

គឺជាកត្តាមួយសំខាន់បំផុតសំរាប់បង្កើនផលិតកម្ម និងទិន្នផលកសិកម្ម ។ ការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ ក៏ជួយបង្កើន តំលៃដី និងផ្តល់អត្ថប្រយោជន៍ជាប្រយោល ដូចជា ចំណីអាហារមានជីវជាតិល្អក្នុងពេញៗមួយឆ្នាំ ទីផ្សារការងារជនបទមានសកម្មភាពខ្លាំងដែលជួយកាត់បន្ថយចំណាកស្រុកចេញ និងសំពាធធ្វើកសិកម្មលើដីមិនអំណោយផល ។

នៅឆ្នាំ២០០៥ ផលិតកម្មកសិកម្មកើន ១៦,៦% រីឯផលិតកម្មផលដំណាំកើន ២៨,០% ។ យោងតាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) មូលហេតុមួយនៃកំណើននេះ គឺការពង្រីកប្រព័ន្ធធារាសាស្ត្រ ។ ថ្វីបើប្រព័ន្ធធារាសាស្ត្រដើរតួនាទីសំខាន់នៅក្នុងកសិកម្មក៏ដោយ ប៉ុន្តែវាទទួលបានការវិនិយោគតិចតួចនៅឡើយពីខាងរដ្ឋ និងវិស័យឯកជន ។ ការវាយតំលៃភាពក្រីក្រនៅកម្ពុជាឆ្នាំ២០០៦ របស់ធនាគារពិភពលោក បានសង្កត់ធ្ងន់អំពីតួនាទីសំខាន់នៃការកែលំអហេដ្ឋារចនាសម្ព័ន្ធដើម្បីបង្កើនផលិតភាព ហើយបានរំលែកថា ត្រូវធ្វើវិនិយោគសាធារណៈច្រើនថែមទៀតដើម្បីពង្រឹងការគ្រប់គ្រងទឹក ។

ដោយមើលឃើញពីសារៈសំខាន់សំរាប់ការអភិវឌ្ឍន៍ប្រទេសនៃប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងធនធានទឹកប្រកបដោយចីរភាព CDRI-វបសអ ដោយរួមសហការជាមួយសាកលវិទ្យាល័យស៊ីដនី (UoS) និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) បានបង្កើតកម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវការគ្រប់គ្រងធនធានទឹក (WRMRCDP) ដោយមានជំនួយគាំទ្រពីអូស្ត្រាលី (AusAID)[១] ។ គំរោងផ្តោតលើការអភិវឌ្ឍន៍

* បណ្ឌិត ធន់ វឌ្ឍនា ជាអ្នកស្រាវជ្រាវនៅ CDRI-វបសអ និងជាអតីតប្រធានក្រុមនៃកម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវការគ្រប់គ្រងធនធានទឹក (WRMRCDP) ហើយលោក ចែម ផល្លា ជាអ្នកស្រាវជ្រាវនៅ CDRI-វបសអ និងបច្ចុប្បន្នជាប្រធានក្រុម WRMRCDP ។

### មាតិកា

បញ្ហាប្រឈមនៃការគ្រប់គ្រងធនធានទឹកនៅកម្ពុជា ........ ១
តើទេសចរណ៍អំណោយផលដល់អ្នកក្រនៅសៀមរាបឬទេ? ........ ៤
ការវិភាគផលប៉ះពាល់សេដ្ឋកិច្ចនៃប្រាក់កំរៃនៅតាមព្រំដែន ........ ៩
តាមដានសេដ្ឋកិច្ច— ស្ថានភាពក្រៅប្រទេស ........ ១២
— ស្ថានភាពក្នុងប្រទេស ........ ១៤
— សន្ទស្សន៍សេដ្ឋកិច្ច ........ ១៧
ព័ត៌មានថ្មីៗពី CDRI-វបសអ ........ ២០

សមត្ថភាពស្រាវជ្រាវក្នុងរយៈពេល៥ឆ្នាំ គិតចាប់តាំងពីខែកក្កដា ២០០៦ និងបានចាប់អនុវត្តជាផ្លូវការនៅដើមខែធ្នូ ២០០៦ ។ នៅក្នុងសិក្ខាសាលាបើកដំណើរការកម្មវិធី គេបានរកឃើញបញ្ហាសំខាន់ៗមួយចំនួនជាប់ទាក់ទិននឹងការគ្រប់គ្រងធនធានទឹក ដូចជា ទំហំនៃប្រព័ន្ធធារាសាស្ត្រ បញ្ហាហិរញ្ញវត្ថុ ការគ្រប់គ្រងទឹកដែលរួមមាន សហគមន៍កសិករប្រើប្រាស់ទឹក (FWUC) និងបញ្ហាជាប់ទាក់ទងនឹងដែនរងទឹកភ្លៀង និងតំបន់អាងនៃស្ទឹងទន្លេ ។




## ទំហំនៃប្រព័ន្ធធារាសាស្ត្រ

ប្រព័ន្ធធារាសាស្ត្រនៅកម្ពុជា គេធ្វើចំណាត់ថ្នាក់ទៅតាម ខ្នាតតូច មធ្យម រឺ ធំ និងទៅតាមតំបន់អេកូឡូជីកសិកម្មសំខាន់ទាំងបី គឺ តំបន់លិចទឹក តំបន់វាលទំនាប និងតំបន់ខ្ពង់រាប ។ ខ្នាតប្រព័ន្ធធារាសាស្ត្រ ចានកំនត់ឡើងទៅ តាមផ្ទៃដីស្រោចស្រព គឺត្រឹម ២០០ហិកតាចុះក្រោម ត្រូវចាត់ទុកជាខ្នាតតូច ពី ២០០ ដល់ ៥.០០០ហិកតា ជាខ្នាតមធ្យម និងលើសពី ៥.០០០ហិកតា ជាខ្នាតធំ ។ បច្ចេកទេសស្រោចស្រពមានប្រើជាទូទៅជាងគេនៅកម្ពុជា រួមមានការយោងទឹកឡើងតាមបែបបុរាណ ស្ថានីយ៍បូមទឹកចល័ត ការបង្ហូរ ទឹកចុះ និងការគួបផ្សំវិធីសាស្ត្រទាំងនេះ ។ ប្រព័ន្ធធារាសាស្ត្រខ្នាតតូចមួយ ចំនួន និងភាគច្រើននៃប្រព័ន្ធខ្នាតមធ្យម និងធំ តែងមានអាងសំរាប់ស្តុកទឹក និងប្រព័ន្ធប្រឡាយសំរាប់ចែកចាយទឹកស្រោចស្រព ។ ក្រសួងធនធានទឹក និងឧតុនិយម (MOWRAM) បានប៉ាន់ស្មានថា នាបច្ចុប្បន្ននៅកម្ពុជា មានជាង ២០០០ប្រព័ន្ធធារាសាស្ត្រ (១.៤១៥ខ្នាតតូច ៥៥៥ខ្នាតមធ្យម និង៣៣ ខ្នាតធំ) ដែលអាចស្រោចស្រពផ្ទៃដីជាងមួយលានហិកតា រឺប្រហែល ៤០% នៃផ្ទៃដីស្រែសរុប ។

នៅក្នុងទសវត្សរ៍១៩៨០ និងដើមទសវត្សរ៍១៩៩០ ការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រភាគច្រើន ផ្តោតលើប្រព័ន្ធខ្នាតតូច ប៉ុន្តែតាមរយៈការបង្កើត MOWRAM នៅឆ្នាំ១៩៩៩ គេបានបំបែរចំនុចផ្តោតទៅលើប្រព័ន្ធខ្នាតមធ្យម និងធំវិញ ដោយសារមានមូលនិធិបានមកទាំងពីខាងរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ ។ នៅក្នុងសិក្ខាសិលាបើកដំណើរការ ពួកអ្នកចូលរួមបានពិភាក្សាពី ភាពសមស្រប ភាពផ្តល់ផលល្អ និងប្រសិទ្ធភាពនៃប្រព័ន្ធមានទំហំខុសៗគ្នា ចំពោះការគ្រប់គ្រង និងស្ថិរភាពសេដ្ឋកិច្ច ដែលពឹងផ្អែកយ៉ាងខ្លាំងលើ អភិបាលកិច្ច ។ ដំណោះស្រាយទំនងជាត្រូវប្រែប្រួលទៅតាមកាលៈទេសៈខុសៗគ្នា ហើយអត្ថបទនេះមិនធ្វើការវិនិច្ឆ័យថា ប្រព័ន្ធខ្នាតណាសមស្របជាងគេសំរាប់ការវិនិយោគនោះទេ ប៉ុន្តែនឹងព្យាយាមលើកមកបង្ហាញពីការគិតគូរជាក់ស្តែងមួយចំនួន និងបញ្ហានានាសំរាប់ការស្រាវជ្រាវនាពេលអនាគត ដែលបានរកឃើញនាពេលធ្វើសិក្ខាសាលាបើកដំណើរការកម្មវិធី ។

តារាងខាងក្រោមបង្ហាញថា ប្រព័ន្ធធារាសាស្ត្រទាំងខ្នាតតូច និងខ្នាតធំមានគុណសម្បត្តិ និងគុណវិបត្តិដូចគ្នា ។ ការពិភាក្សាខាងក្រោម បង្ហាញពីគុណសម្បត្តិ និងគុណវិបត្តិទាំងនេះទាក់ទងនឹងអភិបាលកិច្ចទឹក ។

*ការប្រៀបធៀបប្រភេទប្រព័ន្ធធារាសាស្ត្រ - ខ្នាតតូច និង ខ្នាតធំ*[២]

| បរិយាយ | ប្រព័ន្ធធារាសាស្ត្រខ្នាតតូច | ប្រព័ន្ធធារាសាស្ត្រខ្នាតធំ |
|---|---|---|
| ចំណាយវិនិយោគ | ទាប | ខ្ពស់ |
| ផ្ទៃដីស្រោចស្រព | តូច | ធំ |
| ចំណាយ O&M | ទាប | ខ្ពស់ |
| ការចែកចាយទឹក | ធម្មតា | ស្មុគស្មាញ |
| អ្នកទទួលផល | តិចជាង | ច្រើនជាង |
| ធនធានជលផល | តិចជាង | ច្រើនជាង |
| ការគ្រប់គ្រង | សហគមន៍/FWUC | ថ្នាក់ខេត្ត/ថ្នាក់ជាតិ |
| ទំនាស់ និង ដំណោះស្រាយ | នៅក្នុងសហគមន៍ | ឆ្លងសហគមន៍ច្រើន |
| ចំណេះធ្វើខាងបច្ចេកទេស | ធម្មតា | ស្មុគស្មាញ/ទំនើប |

## អភិបាលកិច្ចទឹក

អភិបាលកិច្ចទឹក សំដៅលើអង្គការ និងស្ថាប័ននានាខាងសង្គមកិច្ច នយោបាយ និងសេដ្ឋកិច្ច ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងនិងអភិវឌ្ឍន៍ទឹកនៅក្នុងសហគមន៍ និងឆ្លងកាត់ព្រំដែនសហគមន៍នានាដែលប្រើប្រាស់ប្រភពទឹករួមគ្នា ។ អភិបាលកិច្ច ផ្តោតលើបញ្ហាថា តើស្ថាប័ននានាត្រូវបង្កើត និងដាក់អនុវត្តច្បាប់និងបទបញ្ញត្តិយ៉ាងដូចម្តេច ដើម្បីបង្កើនប្រសិទ្ធភាព និងសមភាពក្នុងការបែងចែកធនធានទឹក ។

ជាទូទៅ អភិបាលកិច្ចទឹក កកើតចេញពីការរចនារៀបចំខាងបច្ចេកទេសគ្រប់គ្រង និងរបៀបរៀបចំស្ថាប័ន ពិសេសតួនាទីរបស់ FWUC ។ គេបានបង្ហាញគំរូដ៏សាមញ្ញមួយដូចខាងលើ ដើម្បីធ្វើវិភាគពីទំនាក់ទំនងរវាងការរចនារៀបចំខាងបច្ចេកទេសនៃប្រព័ន្ធធារាសាស្ត្រ របៀបដំណើរការនៃ FWUC ព្រមទាំងបញ្ហាប្រឈមក្នុងការគ្រប់គ្រងទឹក និងការដោះស្រាយទំនាស់ ។

### *កត្តាបច្ចេកទេស*

ផលិតភាពដំណាំ អាស្រ័យលើគុណភាពដី គ្រាប់ពូជ និងបរិមាណទឹក ដែលមានសំរាប់មុខដំណាំណាមួយ ។ ប្រព័ន្ធធារាសាស្ត្រខ្នាតតូច មានលក្ខណៈបច្ចេកទេសមិនសូវស្មុគស្មាញ និងអស់សោហ៊ុយតិចជាងក្នុងការសាងសង់ ការកែលំអ និងការដំណើរការ/ថែទាំជួសជុល (O&M) ប៉ុន្តែទំហំដីស្រោចស្រព និងចំនួនអ្នកទទួលផលប្រយោជន៍ គឺមានតិច ។ យោងតាមការយល់ដឹងល្អប្រសើរជាងមុនពីគុណភាពដី ដោយសារផ្ទៃដីមុខសញ្ញាមានទំហំតូចៗ និងដោយសារផលិតភាពដំណាំវាជាប់ទាក់ទងជាមួយទឹក និងគុណភាពដី ដូចនេះប្រព័ន្ធធារាសាស្ត្រខ្នាតតូច អាចជួយរួមចំណែកកែលំអផលិតភាពបានច្រើនជាងមុន ។

ផ្ទុយទៅវិញ ប្រព័ន្ធធារាសាស្ត្រខ្នាតធំ ជាទូទៅតែងមានលក្ខណៈបច្ចេកទេសស្មុគស្មាញ និងត្រូវការទុនវិនិយោគច្រើន ។ ដោយសារផ្ទៃដីគ្របដណ្តប់មានទំហំធំជាង គុណភាពដីក៏ប្រែប្រួលខុសគ្នាច្រើនដែរ ដែលនាំឱ្យមានចោទសំនួរពីករីតដែលទឹកស្រោចស្រព អាចជួយរួមចំណែកបង្កើនផលិតភាព ។ ទោះយ៉ាងនេះក្តី ក៏គេគ្មានសង្ស័យអ្វីពីផលប៉ះពាល់ដ៏ច្រើនទៅលើផលិតកម្ម និងចំនួនប្រជាជនអ្នកទទួលផលនោះទេ ។

ចំពោះការរចនារៀបចំខាងបច្ចេកទេស គេគួរគិតគូរជាសំខាន់ពីសមត្ថភាពហិរញ្ញវត្ថុរបស់សហគមន៍មូលដ្ឋាន ដើម្បីរ៉ាប់រងចំណាយថែទាំជួសជុល ។ ប្រសិនបើកសិករ និងសហគមន៍មូលដ្ឋាន មិនអាចរ៉ាប់រងចំណាយនេះបានទេ ការងារថែទាំជួសជុលនឹងត្រូវធ្លាក់ទៅលើរដ្ឋាភិបាល ។ម្យ៉ាងទៀត

ការរចនារៀបចំប្រព័ន្ធ ត្រូវស្របតាមស្តង់ដារបច្ចេកទេស និងមានការថែទាំជាប្រចាំ ហើយការរៀបចំផែនការផ្គត់ផ្គង់ទឹកមានកំនត់ពេលច្បាស់លាស់ និងមានការចូលរួមទាំងអស់គ្នាពីសហគមន៍អ្នកប្រើប្រាស់ ។ ការរចនារៀបចំប្រព័ន្ធធារាសាស្ត្របានល្អ នឹងជួយរួមចំណែកធ្វើឱ្យការគ្រប់គ្រងធនធានទឹកទទួលបានជោគជ័យ ។

ចំពោះហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រមិនពេញលេញ និងអន់ខ្សោយ វាបង្កបញ្ហាដល់ការគ្រប់គ្រងទឹក ដោយសារហេតុផលជាច្រើនៈ (១) ការចែកចាយទឹកដោយខ្ជះខ្ជាយ និងគ្មានសមធម៌ (២) កំណើនការប្រជែងដណ្តើមទឹករវាងអ្នកប្រើប្រាស់ (៣) ការប្រមូលកំរៃបានតិចលើសេវាកម្មស្រោចស្រព (៤) កង្វះការចូលរួម ។ បញ្ហាទាំងអស់នេះ អាចបង្កទំនាស់នៅក្នុង និងរវាងសហគមន៍ផ្សេងៗ ដែលអាចនាំឱ្យវឹកវរក្នុងសង្គម និងប៉ះពាល់មិនល្អដល់ការបំពេញមុខងាររបស់ FWUC ។

*ការគ្រប់គ្រងបញ្ហាប្រឈម និងការដោះស្រាយទំនាស់*

បើគ្រាន់តែមានទឹកប្រើដោយសារកំណែលំអហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រតែមួយមុខ គេមិនអាចធានាបានពេញលេញឱ្យការប្រើទឹកមានប្រសិទ្ធភាពល្អនោះទេ គឺត្រូវមានការគ្រប់គ្រងទឹកយ៉ាងសក្តិសិទ្ធិថែមទៀត ។ ឧទាហរណ៍ការងារដ៏សំខាន់បំផុតមួយក្នុងការគ្រប់គ្រងទឹកគឺ ការបិទបើកទ្វារទឹក ។ ជារឿយៗ ការបិទបើកទ្វារទឹក បង្កបញ្ហាជាច្រើនទាក់ទងនឹងពេលវេលាការចែកចាយទឹកឱ្យបានស្មើភាព និងការបែងចែក ដូចជា ពេលវេលានិងបរិមាណទឹក ត្រូវបែងចែកឱ្យប្រើនៅខាងលើខ្សែទឹក នៅខាងក្រោមខ្សែទឹក និងបញ្ហាគ្រប់គ្រងការនេសាទ ។ ក្រៅពីការរចនារៀបចំខាងបច្ចេកទេស អ្នកបើកបិទទ្វារទឹក ត្រូវមានចំណេះដឹងបច្ចេកទេសដើម្បីគ្រប់គ្រងទ្វារគឺបិទបើកតាមរបៀបណាមួយដែលកាត់បន្ថយជំលោះរវាងអ្នកប្រើទឹក ។ ចំណេះដឹងបច្ចេកទេស (ឧ. ទឹកត្រូវហូរយឺតប៉ុណ្ណា) អង្គការសហគមន៍មូលដ្ឋាន និងទំរង់ផ្សេងទៀតនៃការងារសង្គម ក៏មានតួនាទីដែរក្នុងការគ្រប់គ្រងជំលោះនានា ។

យោងតាមទំហំប្រព័ន្ធធារាសាស្ត្រ ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រត្រូវមានកំរិតសមត្ថភាពផ្សេងៗគ្នា ដើម្បីគ្រប់គ្រងទឹកស្រោចស្រពឱ្យមានប្រសិទ្ធភាពល្អ និងសក្តិសិទ្ធិ ។ ប្រព័ន្ធធារាសាស្ត្រខ្នាតតូច អាចងាយស្រួលគ្រប់គ្រងសំរាប់ សហគមន៍មូលដ្ឋានដែលមានមូលធនសង្គមជួយឱ្យប្រជាជនអាចធ្វើសហប្រតិបត្តិការលើការគ្រប់គ្រងទឹក ។ ជាទូទៅ FWUC រឺថ្នាក់ឃុំ អាចដោះស្រាយបញ្ហាទាំងនេះបាន ។ ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រខ្នាតធំ មានលក្ខណៈស្មុគស្មាញជាង ដូច្នេះអាចលើសពីសមត្ថភាព រឺសិទ្ធិអំណាចរបស់សហគមន៍នីមួយៗ ។ បញ្ហានេះត្រូវមានសមត្ថភាពខាងស្ថាប័ន និងការវិនិយោគទុនហិរញ្ញវត្ថុច្រើន ដែលជារឿយៗត្រូវមានអន្តរាគមន៍ និងការគាំទ្រពីខាងក្រៅ ដែលមានថ្នាក់ខេត្ត និងថ្នាក់ជាតិ ។ បើគ្មានការគ្រប់គ្រងខាងស្ថាប័ន និងអង្គការចាត់តាំងអោយបានល្អទេ ទឹកមិនអាចគ្រប់គ្រង និងបែងចែកបានល្អទេ ហើយនឹងនាំអោយមានការខ្ជះខ្ជាយទឹក និងកកើតជាទំនាស់ ។ ជាលទ្ធផល ដីនិងទឹក ក៏មានផលិតភាពទាប ដែលធ្វើអោយចោទបញ្ហាដល់លក្ខណៈអាចរស់រានខាងសេដ្ឋកិច្ចនៃគំរោងស្រោចស្រព ។

ដោយសំគាល់ឃើញថា ការផ្តល់ទឹកស្រោចស្រពទៅឱ្យកសិករតែងទទួលបានលទ្ធផលល្អជាង បើសិនអនុវត្តដោយអង្គការចាត់តាំងតាមបែបវិមជ្ឈការនោះ រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយប្រគល់ទំនួលខុសត្រូវលើគ្រប់ផ្នែកទាំងអស់នៃការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ទៅអោយ FWUC ។ គោលនយោបាយសង្កត់ធ្ងន់ទៅលើការចូលរួមរបស់សហគមន៍តាមរយៈ FWUC ដើម្បីដំណើរការ និងថែទាំប្រព័ន្ធធារាសាស្ត្រ ។ ការផ្ទេរទំនួលខុសត្រូវទៅអោយ FWUC លើការគ្រប់គ្រងគំរោងធារាសាស្ត្រ ដូចជាការបង្កើត និងការប្រមូលថ្លៃសេវាស្រោចស្រព (ISF) ជាដើម នឹងជួយកាត់បន្ថយបន្ទុករដ្ឋបាលរបស់រាជរដ្ឋាភិបាល ។ លទ្ធផលមួយនៃគោលនយោបាយ នេះ គឺ FWUC អាចមានឥទ្ធិពលលើគុណភាពសេវាកម្មដែលផ្តល់ទៅអោយ សមាជិកខ្លួន ។

*FWUC: តួនាទី និងរចនាសម្ព័ន្ធ*

គេសង្កេតឃើញថា ទឹកបាត់បង់ច្រើនណាស់នៅក្នុងប្រតិបត្តិការស្រោចស្រពដោយសារកសិករគ្រប់គ្រងទឹកមិនបានល្អ និងប្រព័ន្ធស្រោចស្រពមានលក្ខណៈអន់ខ្សោយ ។ កត្តានេះនាំអោយមានកង្វះទឹកដែលបង្កជាទំនាស់រវាងអ្នកប្រើប្រាស់ទឹក ។ ដើម្បីកែលំអបញ្ហានេះ រាជរដ្ឋាភិបាលកំពុងពង្រឹង ការអនុវត្តន៍គោលនយោបាយជាតិក្នុងការគ្រប់គ្រងទឹកប្រកបដោយចីរភាព រួមទាំង FWUC ផង ។ អង្គការចាត់តាំងទាំងនេះ រួមមានកសិករទាំងអស់ដែលប្រើប្រាស់ទឹកបានពីគំរោងនៅក្នុងតំបន់ធារាសាស្ត្រគោលដៅ ។ FWUC មានគណៈកម្មាធិការរបស់ខ្លួន ដែលមានតួនាទីចំបងគ្រប់គ្រងលើសកម្មភាពប្រចាំថ្ងៃ ដូចជា កិច្ចដំណើរការនិងការថែទាំ ការប្រមូលថ្លៃប្រើទឹក ការចែកចាយទឹក ការដោះស្រាយបញ្ហា និងទំនាក់ទំនងខាងក្រៅ ។

លក្ខណៈពេញច្បាប់នៃ FWUC ដែលផ្អែកលើគោលគំនិតនៃភាពជាម្ចាស់មានការទទួលស្គាល់ពីក្រសួងធនធានទឹក ដែលបានកំនត់ស្តង់ដារនៃ FWUC ដោយបានជ្រើសរើសអ្នកតំណាងរបស់កសិករ តាមរយៈការបោះឆ្នោតដើម្បីបង្កើតគណៈកម្មាធិការ FWUC ។ គេរំពឹងថា គណៈកម្មាធិការ ដែលមានប្រធានម្នាក់ អនុប្រធានពីរនាក់ និងសមាជិកជាច្រើន នឹងបំរើផលប្រយោជន៍សមាជិករបស់ខ្លួន ព្រមទាំងមិនជំពាក់ជំពិននឹងអំពើពុករលួយខាងនយោបាយ ថ្វីបើក្នុងការពិតជាក់ស្តែង ការមិនចូលពាក់ព័ន្ធនឹងអន្តរាគមន៍នយោបាយនៅតែជួបការលំបាក ដោយសារកំហិតហិរញ្ញវត្ថុ និងកាលៈទេសៈផ្សេងៗ ។ ទោះយ៉ាងនេះក្តី ចីរភាពនៃ FWUC មិនពឹងផ្អែកលើការគាំទ្រមួយរយៈៗ ដូចតែងឃើញមានជាពិសេស នៅមុនពេលបោះឆ្នោតសំខាន់ៗនោះទេ ។ តាមពិត វាពឹងផ្អែកច្រើនជាងលើការផ្គត់ផ្គង់ហិរញ្ញវត្ថុឱ្យបានទៀងទាត់ ការពង្រឹងសមត្ថភាពគណៈកម្មាធិការ និងការចូលរួមពីសមាជិកសហគមន៍ ។ ដំណើរការដ៏សមស្របនៃ FWUC ក្នុងការចេញបទប្បញ្ញត្តិផ្សេងៗ ក៏ពឹងផ្អែកផងដែរលើសមាជិកដែលត្រូវបានជ្រើសរើសដោយសេរីនិងយុត្តិធម៌ បទបង្ហាញរបស់ភាគីផ្សេងៗ ការចូលរួមពីប្រជាជនទូទៅ និងគណនេយ្យភាព ។

យោងតាមប្រកាសលេខ៣០៦ ថវិការបស់រដ្ឋាភិបាលជាគោលការណ៍ត្រូវចំណាយទៅលើកិច្ចប្រតិបត្តិការនិងការថែទាំជួសជុល ហើយត្រូវកាត់បន្ថយជាបណ្តើរៗ ដោយផ្ទេរទំនួលខុសត្រូវកាន់តែច្រើនទៅអោយ FWUC ។ ជាអកុសលថវិការបស់រដ្ឋាភិបាលបានផ្តល់សំរាប់តែបញ្ហាបន្ទាន់ ជាជាងសំរាប់ចំណាយប្រតិបត្តិការនិងការថែទាំជួសជុល ដូច្នេះចំណាយទាំងនេះជាសំខាន់បានមកពីបុគ្គលអ្នកនយោបាយ វត្តអារាម និងមួយចំនួនតូចបានពីការប្រមូលថ្លៃប្រើទឹក ។ នៅក្នុងសេដ្ឋកិច្ចទីផ្សារ បន្ទុកចំណាយត្រូវប្រមូលយកពីអ្នកប្រើប្រាស់ ដោយផ្អែកលើបរិមាណប្រើប្រាស់ ។ ប៉ុន្តែតាមការ

*តទៅទំព័រ ៨*

# តើទេសចរណ៍អំណោយផលដល់អ្នកក្រនៅសៀមរាបដែរឬទេ?

*ទូត សុខផល្លី និង ហ៊ីង វុត្ថា បានផ្តល់ព័ត៌មានថ្មីៗពីការអភិវឌ្ឍវិស័យទេសចរណ៍នៅកម្ពុជា និងពិភាក្សាពីផលប៉ះពាល់សេដ្ឋកិច្ចនៃទេសចរណ៍នៅខេត្តសៀមរាបទៅលើប្រជាជនមូលដ្ឋាន និងផ្តល់អនុសាសន៍ខាងគោលនយោបាយសំដៅឱ្យវិស័យនេះហុចផលចំណេញបានច្រើនបំផុតដល់សហគមន៍មូលដ្ឋាន និងប្រជាជនក្រីក្រ ។**

វិស័យទេសចរណ៍នៅកម្ពុជា បាននិងកំពុងរីកចំរើនយ៉ាងលឿននៅទសវត្សរ៍ចុងក្រោយនេះ ហើយបានក្លាយជាប្រភពសំខាន់ទីពីរនៃកំណើន បន្ទាប់ពីវិស័យកាត់ដេរ ។ នៅឆ្នាំ២០០៧ គេរំពឹងថាវានឹងផ្តល់ចំណូល ៧១៨,៣ លានដុល្លារតាមរយៈសកម្មភាពសេដ្ឋកិច្ចផ្ទាល់ រឺប្រហែល ៩,៣% នៃ ផសស និង ១.៥៦១,៩លានដុល្លារ តាមរយៈសកម្មភាពសេដ្ឋកិច្ចទាំងផ្ទាល់ និងមិនផ្ទាល់ ។ វិស័យនេះក៏រំពឹងថា នឹងបង្កើតការងារផ្ទាល់និងមិនផ្ទាល់ ដល់ទៅ ១.១០៨.០០០ការងារ រឺ ១៥,៨% នៃចំនួនការងារសរុបក្នុងឆ្នាំនេះ[១] ។ សៀមរាប ដែលមានប្រាសាទអង្គរវត្តដ៏ល្បីល្បាញទាក់ទាញទេសចរបំផុតនោះ បានរីកលូតលាស់យ៉ាងលឿនខាងទេសចរណ៍ ទាំងចំនួនភ្ញៀវមកដល់ទេសភាពទីក្រុង និងសេវាកម្ម/កន្លែងបំរើការទេសចរណ៍ ។ នៅឆ្នាំ២០០៦ មានទេសចរបរទេសចូលសរុប ៨៥៦.៥១០នាក់ រឺ ប្រហែល ៥០% នៃទេសចរចូលមកកម្ពុជា និងជាកំណើនយ៉ាងខ្ពស់ បើធៀបនឹងតួលេខ ២៦៤.០០០នាក់ នៅឆ្នាំ២០០១ (ក្រសួងទេសចរណ៍ ឆ្នាំ២០០៦) ។

ទោះបីមានកំនើនយ៉ាងរហ័សបែបនេះក្តី អ្នកខ្លះរិះគន់ថា ផលចំណេញនៃវិស័យទេសចរណ៍នៅសៀមរាប មិនបានបែងចែកស្មើភាពល្អទេ ក្នុងចំណោមស្រទាប់សង្គមនានា សកម្មភាពសេដ្ឋកិច្ចផ្សេងៗ និងទីតាំងខុសៗគ្នា (World Bank, 2006; Ballard, 2005 & EIC, 2005) ។ អ្នកក្រទទួលបានផលតិចពីការអភិវឌ្ឍន៍ទេសចរណ៍ ដូច្នេះហើយវិស័យទេសចរណ៍មិនបានជួយកាត់បន្ថយភាពក្រីក្រនៅក្នុងខេត្ត ឱ្យបានច្រើនដូចការរំពឹងទុកនោះទេ ។ ជាលទ្ធផល សៀមរាបនៅតែស្ថិតក្នុងចំណោមខេត្តក្រីក្រជាងគេនៅកម្ពុជា ដដែល ។ ដើម្បីស្វែងយល់បានច្បាស់ថែមទៀតពីស្ថានភាពដ៏លំបាកនេះ CDRI-វបសអ បានធ្វើវិភាគពីការបែងចែកផលចំណេញនៃវិស័យទេសចរណ៍ ដោយពិនិត្យលើសំនួរដូចតទៅ: (១) តើចំណងទាក់ទងរវាងឧស្សាហកម្មទេសចរណ៍ និងសេដ្ឋកិច្ចនៅមូលដ្ឋាន មានរចនាសម្ព័ន្ធ និងលក្ខណៈបែបណា? (២) តើមានយន្តការអ្វីខ្លះសំរាប់ផ្ទេរផលចំណេញនៃវិស័យទេសចរណ៍ទៅឱ្យសហគមន៍មូលដ្ឋាន? (៣) តើរដ្ឋាភិបាលថ្នាក់ជាតិ អាជ្ញាធរមូលដ្ឋាន សង្គមស៊ីវិល អ្នកផ្តល់ជំនួយ និងវិស័យឯកជន ត្រូវបំពេញតួនាទីអ្វីខ្លះ ដើម្បីឱ្យមានផលចំណេញនៃវិស័យទេសចរណ៍ បានច្រើនថែមទៀតដល់សហគមន៍មូលដ្ឋាន និងប្រជាជនក្រីក្រ? ខាងក្រោមនេះជាសេចក្តីសង្ខេបនៃលទ្ធផលរកឃើញសំខាន់ៗក្នុងការសិក្សា ។

## ការបង្ហាញត្រួសៗពីការអភិវឌ្ឍន៍វិស័យទេសចរណ៍នៅកម្ពុជា

### *ការអភិវឌ្ឍន៍ និងគោលនយោបាយខាងទេសចរណ៍*

វិស័យទេសចរណ៍នៅកម្ពុជា បានផ្លាស់ប្តូរពីភាពអកម្មស្ងប់ស្ងាត់ មានតួនាទីតិចតួចក្នុងការអភិវឌ្ឍន៍ប្រទេស តាមលំនាំនាចុងទសវត្សរ៍១៩៨០-ដើមទសវត្សរ៍១៩៩០ ទៅជាប្រភពកំនើនដ៏ខ្លាំងក្លាមួយនៃសេដ្ឋកិច្ចកម្ពុជា ។ ចំនួនភ្ញៀវទេសចរបរទេស បានកើនយ៉ាងខ្លាំងនៅអំឡុងឆ្នាំ១៩៩៥-២០០៦ តាមអត្រាមធ្យមប្រចាំឆ្នាំ ២០,៤% ពីចំនួន ០,២៩លាននាក់ នៅឆ្នាំ១៩៩៥ ដល់ ១,៧០លាននាក់ នៅឆ្នាំ២០០៦ ។ កន្លែងបំរើការ និងសេវាកម្មទេសចរណ៍ ដែលមានសណ្ឋាគារ ផ្ទះសំណាក់ ទីភ្នាក់ងារទេសចរណ៍ និងភោជនីយដ្ឋាន ក៏រីកដុះដាលយ៉ាងរហ័សដែរ (តារាង ១) ។ ការរីកលូតលាស់វិស័យនេះផុសចេញពី: (១) ការទទួលបានសន្តិភាព និងស្ថិរភាព ចាប់តាំងពីដើមទសវត្សរ៍១៩៩០ (២) មានកន្លែងទាក់ទាញទេសចរច្រើន (ឧ. ទេសចរណ៍វប្បធម៌ អេកូទេសចរណ៍ និងទេសចរណ៍ធម្មជាតិ) (៣) កំនើនការធ្វើដំណើរជាលក្ខណៈអន្តរជាតិ និងក្នុងស្រុក និង (៤) គោលនយោបាយអភិវឌ្ឍន៍របស់រដ្ឋាភិបាលដែលផ្តោតជាសំខាន់លើការអភិវឌ្ឍន៍វិស័យទេសចរណ៍ ដូចជាគោលនយោបាយបើកចំហជើងមេឃ ទិដ្ឋាការផ្តល់ឱ្យនៅពេលភ្ញៀវមកដល់ និងការលើកលែងទិដ្ឋាការចំពោះជនកម្ពុជាដែលរស់នៅបរទេស ។

គោលនយោបាយទេសចរណ៍ នៅដើមទសវត្សរ៍១៩៩០ សំដៅជាសំខាន់ទាក់ទាញភ្ញៀវទេសចរឱ្យបានកាន់តែច្រើន ដោយផ្តោតលើការអភិវឌ្ឍន៍ ផលិតផលទេសចរណ៍ ការកែលំអនិងជួយសំរួលការចូលមកនិងធ្វើដំណើរក្នុង ប្រទេស ការអភិវឌ្ឍន៍ទីផ្សារអន្តរជាតិ និងការពង្រឹងការងារអភិវឌ្ឍន៍ធនធានមនុស្សនៃរដ្ឋបាលទេសចរណ៍របស់រដ្ឋ ។ ដោយសារវិស័យទេសចរណ៍បានរីកចំរើនយ៉ាងលឿន ហើយការកាត់បន្ថយភាពក្រីក្របានក្លាយជាគោលដៅចំបងនៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចរបស់រដ្ឋាភិបាល ដូច្នេះយុទ្ធសាស្ត្រទេសចរណ៍បច្ចុប្បន្ន មិនត្រឹមតែផ្តោតលើការជំរុញកំនើនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកែលំអឱ្យផលចំណេញទេសចរណ៍អាចបែងចែកទៅដល់សហគមន៍មូលដ្ឋាន និងអ្នកក្រីក្របានកាន់តែប្រសើរថែមទៀត ។ ក្នុងបរិបទ នេះ ផែនការទេសចរណ៍បច្ចុប្បន្ន ត្រូវឈរលើគោលការណ៍ដែលថា ការអភិវឌ្ឍន៍វិស័យទេសចរណ៍ត្រូវជួយរួមចំណែកកាត់បន្ថយភាពក្រីក្រ និងធានាឱ្យចំណូលវិស័យទេសចរណ៍មានការបែងចែកប្រកបដោយសមធម៌ ទៅតាមបែបបទមួយមានផែនការល្អ និងការគ្រប់គ្រងល្អ ។

**តារាង១ : ភ្ញៀវទេសចរណ៍ និងសេវាកម្មទេសចរណ៍ ឆ្នាំ១៩៩៨-២០០៦**

| | 1998 | | 2001 | | 2006 | |
|---|---|---|---|---|---|---|
| | *សរុប* | *សៀមរាប* | *សរុប* | *សៀមរាប* | *សរុប* | *សៀមរាប* |
| ភ្ញៀវទេសចរបរទេស (ពាន់នាក់) | 290 | - | 605 | 264 | 1700 | 856 |
| សណ្ឋាគារ | 216 | 24 | 247 | 47 | 351 | 91 |
| ផ្ទះសំណាក់ | 147 | 23 | 370 | 112 | 742 | 171 |
| ភ្នាក់ងារទេសចរណ៍ | 137 | - | 226 | 88 | 382 | 163 |
| មគ្គុទ្ទេសទេសចរណ៍ | 369 | 280 | 727 | 603 | 2712 | 1978 |

*ប្រភព: សៀវភៅស្ថិតិឆ្នាំ២០០៥ របស់វិទ្យាស្ថានជាតិស្ថិតិ និងរបាយការណ៍ស្ថិតិទេសចរណ៍ប្រចាំឆ្នាំរបស់ក្រសួងទេសចរណ៍*

---

* ទូត សុខផល្លី ជាអ្នកស្រាវជ្រាវ និង ហ៊ីង វុត្ថា ជាប្រធានស្រាវជ្រាវផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្មនៅ CDRI-វបសអ ។

### *ទេសចរណ៍ កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ*

ដោយមានកំនើនយ៉ាងទៀងទាត់ វិស័យទេសចរណ៍កម្ពុជាមានតួនាទីយ៉ាងសំខាន់ក្នុងការជួយជំរុញកំណើនសេដ្ឋកិច្ច ។ ចំនែកនៃវិស័យទេសចរណ៍នៅក្នុង ផសស គិតជាតំលៃបន្ថែមដុល (Gross Value Added: GVA) បានកើនឡើងយ៉ាងលឿននៅឆ្នាំ១៩៩៣-២០០៤ ដោយមានកំណើនមធ្យមប្រចាំឆ្នាំ ២៨% ។ តំលៃបន្ថែមដុលខាងទេសចរណ៍គិតតាមថ្លៃថេរឆ្នាំ២០០០ គឺ ២.០២២,៤៩ពាន់លានរៀល (៥០៣,៦១លានដុល្លារ) រឺ ១១,២% នៃ ផសស នៅឆ្នាំ២០០៤ ធៀបនឹង ១៧៧,១៣ពាន់លានរៀល (៦៤,៤៨លានដុល្លារ) រឺ ២,១% នៃ ផសស នៅឆ្នាំ១៩៩៣ ហើយចំណាយប៉ាន់ស្មានរបស់ភ្ញៀវទេសចរ គឺ ៧៤៤,៥១លានដុល្លារ នៅឆ្នាំ២០០៤ ។ ដោយវិស័យ ទេសចរណ៍រំពឹងថានឹងបន្តកើនឡើង ដូច្នេះវាមានសារៈសំខាន់កាន់តែខ្លាំង សំរាប់ជួយទ្រទ្រង់កំណើនសេដ្ឋកិច្ចនៅកម្ពុជា ។

ទោះបីវិស័យទេសចរណ៍ជាក្បាលម៉ាស៊ីននៃកំណើនក្តី ប៉ុន្តែផលប៉ះពាល់របស់វាទៅលើសេដ្ឋកិច្ចមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ គឺនៅមាន កំរិត ។ លោក Ballard (២០០៥) បានរកឃើញថា ផលចំនេញពីវិស័យ ទេសចរណ៍ មិនបានបែងចែកស្មើភាពល្អទេ ហើយប្រជាជនទទួលផលប្រយោជន៍ពីការងារក្នុងវិស័យសាងសង់ សេវាកម្ម និងសិប្បកម្ម បានច្រើនជាងពីវិស័យកសិកម្ម ។ វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (EIC 2005) ក្នុងឯកសារធនាគារពិភពលោក (២០០៦) បានរកឃើញថា ការងារភាគច្រើនដែលប្រជាជនមូលដ្ឋានរកបាន គឺការងារសាងសង់គ្មានជំនាញ រីឯការងារជាប់លាប់ជាងនេះនៅក្នុងវិស័យផ្សេងៗទៀត គឺមានមិនសូវច្រើនទេ ។

**តារាង ២: តំលៃបន្ថែមដុលនៃវិស័យទេសចរណ៍ និងចំណាយរបស់ទេសចរ**

| | 1994 | 1998 | 2001 | 2004[3] |
|---|---|---|---|---|
| តំលៃបន្ថែមដុលនៃវិស័យទេសចរណ៍ (លានដុល្លារ) | 87.69 | 106.1 | 340.6 | 503.6 |
| ចំណាយរបស់ភ្ញៀវទេសចរណ៍ (លានដុល្លារ) | 88.19 | 121.04 | 427.5 | 744.5 |
| ចំណែកនៃតំលៃបន្ថែមដុលក្នុង ផសស | 2.4% | 3.5% | 9.0% | 11.2% |

*ប្រភព : សៀវភៅស្ថិតិប្រចាំឆ្នាំ២០០៥ របស់វិទ្យាស្ថានជាតិស្ថិតិ*

### **ផលប៉ះពាល់ទេសចរណ៍លើប្រជាមូលដ្ឋាន នៅជុំវិញក្រុងសៀមរាប**

លទ្ធផលរកឃើញចុះក្នុងផ្នែកនេះ ផ្អែកលើអង្កេតលើ ៥០៦គ្រួសារ និងការពិភាក្សារបស់ ១០ក្រុមពិភាក្សាស្នូល (focus group discussion: FGDs) ដែលបានធ្វើឡើងនៅ ៨ភូមិ ក្នុងខេត្តសៀមរាបគឺ តាចេក ស្រះស្រង់ខាងជើង ទឹកថ្លា សណ្តាន់ ព្រះដាក់ តាត្រៃ លលៃ និងគោកត្រាច ។ ការសិក្សានេះពិនិត្យពីផលប៉ះពាល់នៃវិស័យទេសចរណ៍ទៅលើប្រជាជនមូលដ្ឋានក្នុងបញ្ហា *ការងារ ប្រាក់ចំណូល ទីផ្សារដីធ្លី និងសុខមាលភាពទូទៅ* ។ ការវិភាគផ្តោតលើវិសាលភាព និងកំរិតនៃផលប៉ះពាល់ទៅលើស្រទាប់សង្គមខុសៗគ្នា (ចាត់ថ្នាក់ជា *ក្រ* និង *មិនក្រ*[៤]) និងសហគមន៍ប្រភេទផ្សេងៗ ដោយផ្អែកលើចំងាយទៅកាន់ក្រុងសៀមរាប រឺតំបន់ប្រាសាទ (ចាត់ថ្នាក់ជា *នៅជិត* និង *នៅឆ្ងាយ*[៥]) ។

### *ផលប៉ះពាល់ផ្នែកឱកាសការងារ*

នៅក្នុងគំរូតាងនេះ វិស័យទេសចរណ៍ បានបង្កើតការងារថ្មីមួយចំនួនដោយបំបែរការងារពីកសិកម្ម ទៅខាងឧស្សាហកម្មនិងសេវាកម្ម នៅជុំវិញទីរួមខេត្តសៀមរាប ប៉ុន្តែក្នុងកំរិតមួយតូចនៅឡើយ ។ ជាងមួយភាគបីនៃអ្នករកចំណូលនៅក្នុងគ្រួសារបានធ្វើអង្កេត មានការងារពាក់ព័ន្ធនឹងវិស័យទេសចរណ៍ ដូចជា ការងារសាងសង់ បុគ្គលិកសណ្ឋាគារនិងភោជនីយដ្ឋានការីទេសចរណ៍កំសាន្ត ជំនួញតូចតាច ដឹកជញ្ជូន ផលិតកម្មនិងទីផ្សារសិប្បកម្ម/វត្ថុអនុស្សាវរីយ៍ ឆ្មាំប្រាសាទ រឺបុគ្គលិកគ្រប់គ្រងតំបន់ទេសចរណ៍ និងការងារកសិកម្មមួយចំនួនសំរាប់ទីផ្សារទេសចរណ៍ ។ សហគមន៍នៅជិតមានសមាមាត្រអ្នកធ្វើការក្នុងទេសចរណ៍ ច្រើនជាងសហគមន៍នៅឆ្ងាយ ហើយអ្នកក្រមានការពាក់ព័ន្ធច្រើនជាងអ្នកមិនក្រ ។ ប៉ុន្តែការងារភាគច្រើនដែលអ្នកក្រនិងសហគមន៍នៅឆ្ងាយទទួលបាន គឺជាការងារមានប្រាក់កំរៃតិច ដូចជា កម្មករសំណង់គ្មានជំនាញ ឆ្មាំប្រាសាទ អ្នកបោសសំអាត និងអ្នកលក់ដូរតូចតាច ។

*តារាង ៣: រចនាសម្ព័នការងារតាមចំណាត់ថ្នាក់ទេសចរណ៍ ២០០២-២០០៦*

| *សកម្មភាព* | ទេសចរណ៍ | | មិនមែនទេសចរណ៍ | |
|---|---|---|---|---|
| *ឆ្នាំ* | **2002** | **2006** | **2002** | **2006** |
| *ប្រភេទសហគមន៍* | គិតជាភាគរយ | | | |
| *ជិត* | 43 | 47 | 57 | 53 |
| *ឆ្ងាយ* | 20 | 26 | 80 | 74 |
| *ចំណាត់ថ្នាក់សុខមាលភាព* | គិតជាភាគរយ | | | |
| *អ្នកក្រ* | 32 | 39 | 68 | 61 |
| *អ្នកមិនក្រ* | 30 | 34 | 70 | 66 |
| *សរុប* | **31** | **36** | **69** | **64** |

*ប្រភព: អង្កេតរបស់CDRI -វបសអ លើ ៥០៦គ្រួសារ ក្នុងខេត្តសៀមរាប នៅខែឧសភា ឆ្នាំ២០០៦*

នៅចន្លោះឆ្នាំ ២០០២ និង ២០០៦ រចនាសម្ព័ន្ធការងារជាទូទៅពុំមានផ្លាស់ប្តូរអ្វីច្រើនទេ ។ នៅឆ្នាំ២០០៦ អ្នករកប្រាក់ចំណូលនៅមូលដ្ឋាន ៤៥% ធ្វើការក្នុងវិស័យកសិកម្ម ដោយធ្លាក់ចុះពី ៤៩% នៅឆ្នាំ២០០២ ហើយមាន ១៨% និង ៣៧% ធ្វើការក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម ដោយកើនពី ១៦% និង ៣៥% នៅឆ្នាំ២០០២ ។ មានហេតុផលសំខាន់ពីរនៃការប្រែប្រួលកំរិតទាបនេះ ។ ទីមួយ ការសិក្សាទើបបានធ្វើនាពេលថ្មីៗ ដូច្នេះ ការផ្លាស់ប្តូរជាច្រើនក្នុងរចនាសម្ព័ន្ធការងារប្រហែលបានកើតមានរួចទៅហើយ នៅពេលធ្វើអង្កេត ។ ទីពីរ ការងារថ្មីភាគច្រើនដែលកើតចេញពីវិស័យទេសចរណ៍ គឺពួកជនចំណាកស្រុកមកពីតំបន់ផ្សេងទៀតប្រមូលយកអស់ ។ ឧទាហរណ៍ ការងារដូចជា អ្នករត់ម៉ូតូឌុប និងអ្នករត់យានទុកទុក គឺធ្វើឡើងដោយអ្នកមកពីក្រៅមូលដ្ឋាន ភាគច្រើនមកពីខេត្តកំពង់ចាម ខេត្តកណ្តាល ខេត្តបាត់ដំបង និងខេត្តព្រៃវែង ។

### *ផលប៉ះពាល់ផ្នែកចំណូល*

វិស័យទេសចរណ៍ ជាប្រភពរកចិញ្ចឹមជីវិតដ៏សំខាន់មួយរបស់ប្រជាជនមូលដ្ឋាន ។ យោងតាមអង្កេត ចំណូលជាមធ្យមពីវិស័យទេសចរណ៍ តំណាងឱ្យប្រហែល ៤៧% នៃចំណូលគ្រួសារសរុបនៅឆ្នាំ២០០៦ ដែលជាកំរិតមួយដ៏ខ្ពស់[៦] ។ សហគមន៍នៅជិត ទទួលផលពីវិស័យទេសចរណ៍បានច្រើនជាងសហគមន៍នៅឆ្ងាយ ទាំងចំណូលសុទ្ធបានពីវិស័យទេសចរណ៍ និងចំណូល

**តារាង ៤: ចំណូលគ្រួសារ និងសូចនាករវិស័យទេសចរណ៍**

| | ចំណូលគិតជាមធ្យម/គ្រួសារ | ចំណូលទេសចរណ៍មធ្យម/គ្រួសារ | ចំនែកនៃចំណូលទេសចរណ៍ |
|---|---|---|---|
| ប្រភេទសហគមន៍ | *គិតជា ម៉ឺនរៀល* | | *គិតជាភាគរយ* |
| *នៅជិត* | 830.1 | 334.2 | 49 |
| *នៅឆ្ងាយ* | 393.2 | 161.7 | 45 |
| ក្រុមសុខមាលភាព | | | |
| *ក្រ* | 316.6 | 154.3 | 49 |
| *មិនក្រ* | 813.6 | 310.4 | 45 |
| សរុប | **600** | **243.3** | **47** |

*ប្រភព : អង្កេតរបស់CDRI -វិបសអ ទៅលើ ៥០៦គ្រួសារ ក្នុងខេត្តសៀមរាប នៅខែឧសភា ឆ្នាំ២០០៦*

វិស័យទេសចរណ៍គិតភាគរយនៃចំណូលសរុប ។ ខណៈដែលអ្នកក្រច្រើនមានការពឹងផ្អែកលើវិស័យទេសចរណ៍ខ្លាំងជាងអ្នកមិនក្រ ចំណូលសុទ្ធពីវិស័យទេសចរណ៍របស់ពួកគេ វាទាបជាខ្លាំងធៀបនឹងចំណូលរបស់អ្នកមិនក្រ ។

វិស័យទេសចរណ៍ក៏ជាកត្តាមួយសំខាន់ណាស់ដែរ សំរាប់បង្កើនចំណូលសរុបរបស់គ្រួសារ ។ ប្រជាជននៅក្នុងអង្កេតយល់ឃើញថា គ្រួសារប្រហែល ៥០% មានកំណើនក៏រិតប្រាក់ចំណូលនៅអំឡុងឆ្នាំ២០០២-២០០៦ ។ ប្រហែល ៥០%នៃមូលហេតុនៃកំនើនដែលបានលើកឡើងជាប់ទាក់ទិននឹងវិស័យទេសចរណ៍ ដូចជា កំណើនចំនួនអ្នករកចំណូលក្នុងគ្រួសារដែលមានការងារធ្វើក្នុងវិស័យទេសចរណ៍ កំណើនផលិតកម្មកសិកម្មសំរាប់ទីផ្សារទេសចរណ៍ កំណើនការងារថ្មីខាងទេសចរណ៍ និងកំណើនថ្លៃដីធ្លី ។ គួរកត់សំគាល់ជាសំខាន់ថា គ្រួសារ ២៦% បានរាយការណ៍ពីការធ្លាក់ចុះចំនូលនៅអំឡុងឆ្នាំ២០០២-២០០៦ ប៉ុន្តែគេបានលើកឡើងពីកត្តាខាងសង្គមកិច្ចមិនមែនទេសចរណ៍ទេ ដូចជា ជំងឺ បំណុល និងវិបត្តិគ្រួសារជាដើម ។

**តារាង ៥ : ការទិញលក់ដី**

| | ការលក់ដី | | ការទិញដី | |
|---|---|---|---|---|
| | គ្រួសារ (%) | ផ្ទៃដីមធ្យម/គ្រួសារ ($m^2$) | គ្រួសារ (%) | ផ្ទៃដីមធ្យម/គ្រួសារ ($m^2$) |
| ក្រក្រី | 21.7 | 4389.6 | 8.3 | 10438.9 |
| មិនក្រីក្រ | 31.3 | 5636.1 | 18.1 | 11505.1 |
| សរុប | **27.1** | **5208.5** | **13.9** | **11230.9** |

*ប្រភព: អង្កេតរបស់CDRI -វិបសអ លើ ៥០៦គ្រួសារ ក្នុងខេត្តសៀមរាប នៅខែឧសភា ឆ្នាំ២០០៦*

### *ផលប៉ះពាល់ផ្នែកដីធ្លី*

វិស័យទេសចរណ៍ មានផលប៉ះពាល់គួរកត់សំគាល់ទៅលើថ្លៃដីធ្លី នៅក្នុងនិងជុំវិញក្រុងសៀមរាប ដូចអាចមើលឃើញតាមកំនើនចំនួននៃការទិញលក់ដីជាពិសេសតាំងពីចុងទសវត្សរ៍១៩៩០ ដែលធ្វើឱ្យដីធ្លីឡើងថ្លៃយ៉ាងគំហុក ។អង្កេតបង្ហាញថា គ្រួសារប្រហែល ២៧% បានលក់ដីរបស់ខ្លួនមួយភាគ រីឯ គ្រួសារប្រហែល ២៧% បានទិញដីបន្ថែមខ្លះ ។ ហេតុផលចំបងនៃការលក់ដី មានដូចជា ការសង់ផ្ទះថ្មី តំរូវការចំណាយនិងប្រើប្រាស់ក្នុងគ្រួសារ ការវិនិយោគលើទ្រព្យសកម្មនិងជំនួញមានផលិតភាពជាង និងការធ្វើកសិកម្មមិនបានផល ។

ការលក់ដី អាចមានឥទ្ធិពលទាំងវិជ្ជមាន និងអវិជ្ជមាន លើប្រជាជនមូលដ្ឋាន ទៅតាមការប្រើប្រាស់ប្រាក់ដែលទទួលបានពីការលក់ដី ។ បើសិនប្រាក់នោះបានយកទៅប្រើឱ្យមានផលិតភាព ដូចជា ទិញទ្រព្យសកម្មបំរើផលិតកម្ម រឺធ្វើដើមទុនដើម្បីជំរុញសកម្មភាពជំនួញ រឺធ្វើវិនិយោគលើការអប់រំកុមារ ដូចនេះការលក់ដីអាចជួយលើកស្ទួយសុខមាលគ្រួសារ ។ ផ្ទុយទៅវិញ ការលក់ដី ជាពិសេសដីស្រែ អាចនាំឱ្យខាតបង់ ដោយសារគ្រួសារត្រូវបាត់បង់ប្រភពរកចិញ្ចឹមជីវិត ជាពិសេស បើសិនគ្មានការងារអ្វីផ្សេងធ្វើ ។ តាមមតិរបស់ប្រជាជនមូលដ្ឋាន ការលក់ដី គឺជារឿងល្អណាស់ ហើយវាមានផលប៉ះពាល់វិជ្ជមានចំពោះប្រជាជនមូលដ្ឋាន និងសហគមន៍ ។ នៅកន្លែងមានទីផ្សារដីធ្លីសកម្ម ដូចជានៅភូមិតាចេកជាដើម ប្រជាជនមានការរីកចំរើនគុណភាពផ្ទះសំបែង និងកំណើនចំនួនម៉ូតូ ។ អ្នកលក់ដីមួយចំនួនបានទិញដីធំជាងមុននៅតំបន់ផ្សេងទៀតឆ្ងាយពីភូមិសំរាប់ធ្វើកសិកម្ម ហើយក្លាយជាអ្នកធូរធារជាងមុន ។ ប៉ុន្តែអ្នកក្រច្រើនតែប្រើប្រាស់ប្រាក់ទាំងអស់បានពីការលក់ដី សំរាប់ដោះស្រាយចំណាយលើការប្រើប្រាស់ក្នុងគ្រួសារ ដូចជា កែលំអផ្ទះសំបែង ទិញទ្រព្យសកម្មមិនបំរើការផលិត រឺចំណាយរៀបការកូនចៅ ។ ពួកគេឈប់ធ្វើកសិកម្ម ហើយទៅពឹងផ្អែកលើការលក់ពលកម្មប្រចាំថ្ងៃ និង

**ប្រអប់ ១: ក្រុមគ្រួសារមួយ មានជីវភាពកាន់តែលំបាក ក្រោយពីការលក់ដីកសិកម្ម**

គ្រួសារក្រមួយនៅភូមិតាចេក មាន កូនប្រុស ៣នាក់ (អាយុ ២៣ ២១ និង ១៧ឆ្នាំ) និងកូនស្រីម្នាក់អាយុ ១៤ឆ្នាំ ។ កូនប្រុសច្បងបានរៀបការ ហើយបានទៅរស់នៅក្រៅភូមិ ។ កូនប្រុសច្បងបន្ទាប់ បានចាកចេញពីភូមិទៅភ្នំពេញ ហើយពុំមានដំណឹងទេ ។ ឪពុកម្ដាយមានការអប់រំតិចណាស់ ហើយបច្ចុប្បន្នមានតែកូនស្រីម្នាក់នោះទេដែលនៅរៀន ។

មុនឆ្នាំ២០០២ គ្រួសារនេះ ធ្វើស្រែពីរដងក្នុងមួយឆ្នាំ ហើយបានផលស្រូវលើសពីតំរូវការបរិភោគក្នុងគ្រួសារ ប៉ុន្តែមិនច្រើនដល់អាចសន្សំប្រាក់បានទេ ។ នៅឆ្នាំ២០០២ កូនប្រុសច្បងបានរៀបការ ហើយគឺជាពេលដែលគ្រួសារនេះបានប្រែប្រួលជោគវាសនា ។ ដើម្បីបង់ថ្លៃបណ្ដាការសំរាប់មង្គលការកូនប្រុស ឪពុកម្ដាយបានលក់ដីកសិកម្មទាំងអស់ (ប្រហែលកន្លះហិកតា) បានប្រហែល ៨០០ដុល្លារ ។ បុរសជាប្ដីក៏ឈប់ធ្វើកសិកម្ម ហើយទៅធ្វើការងារសំណង់ប្រចាំថ្ងៃ ។ ដោយសារគាត់មានសុខភាពមិនសូវល្អ គាត់ធ្វើការបានតែ ២០ថ្ងៃប៉ុណ្ណោះ ក្នុងមួយខែ ហើយរកចំណូលបាន ៨០០០រៀល/ថ្ងៃ ។ ក្រោយមក កូនប្រុសពៅបានតាមឪពុកទៅធ្វើការងារសំណង់ ដោយរកបាន ៧០០០រៀល/ថ្ងៃ ។ ពេលខ្លះពួកគាត់ខ្ចីប្រាក់គេ ដើម្បីដោះស្រាយការចំណាយប្រចាំថ្ងៃ និងការព្យាបាលជំងឺ ។

*ប្រភព: ការចុះសិក្សាដល់កន្លែងតាមបែបគុណភាពរបស់ CDRI -វិបសអ នៅខេត្តសៀមរាប ខែឧសភា-កក្កដា ឆ្នាំ២០០៦*

ការងារមិនទៀងទាត់ដែលមានហានិភ័យខ្ពស់ ។

### *ផលប៉ះពាល់ផ្នែកសុខមាលភាព*

ការអភិវឌ្ឍន៍វិស័យទេសចរណ៍ បានរួមចំណែកដល់ការកែលំអសុខមាលភាពប្រជាជនមូលដ្ឋាន ។ ប្រហែលពាក់កណ្តាលនៃគ្រួសារសរុបបានរាយការណ៍តាមការយល់ឃើញផ្ទាល់ថា សុខមាលភាពរបស់ខ្លួនបានប្រសើរឡើង ធៀបនឹង ៥ឆ្នាំមុន ។ ការប្រសើរឡើងនេះ នាំឱ្យភាគរយគ្រួសារក្រីក្រធ្លាក់ចុះយ៉ាងច្រើននៅឆ្នាំ២០០៦ ធៀបនឹងឆ្នាំ២០០២ ។ នៅឆ្នាំ២០០៦ គ្រួសារ ៣៨% បានទទួលស្គាល់ខ្លួនឯងថាជាគ្រួសារក្រីក្រ ធៀបនឹង ៥៥% នៅឆ្នាំ២០០២ ។ ចំពោះគ្រួសារក្នុងសហគមន៍ក្រីក្រដែលរាយការណ៍ពីភាពល្អប្រសើរនៃសុខមាលភាពរបស់ខ្លួន នៅក្នុងសហគមន៍ដែលនៅឆ្ងាយ គឺមានចំនួនភាគរយច្រើនជាងនៅសហគមន៍នៅជិត ។ កត្តាដែលនាំឱ្យមានហេតុការណ៍បែបនេះ គឺនៅឆ្នាំគោល (២០០២) សហគមន៍នៅឆ្ងាយមានប្រជាជនភាគច្រើនជាអ្នកក្រដែលមានប្រាក់ចំណូលទាបជាមូលដ្ឋាន ។ ដូច្នេះកំណើននៃចំណូលទោះបីក្នុងកំរិតតិចតួចក្តី ក៏នាំឱ្យមានចំណាប់អារម្មណ៍ថាសុខមាលភាពបានប្រសើរឡើងយ៉ាងច្រើនដែរ ។ សំរាប់គ្រប់គ្រួសារ ភាពប្រសើរឡើងនៃសុខមាលភាព វាផុសចេញជាសំខាន់ពីកត្តាទេសចរណ៍ ដូចជាកំណើនប្រាក់ចំណូលភាគច្រើនបានមកពីវិស័យទេសចរណ៍ ផ្ទះស្នាក់នៅល្អជាងមុន ហេដ្ឋារចនាសម្ព័ន្ធកាន់តែប្រសើរ និងថ្លៃ/តំលៃដីកាន់តែខ្ពស់ ។

គ្រួសារដែលរាយការណ៍ពីការធ្លាក់ចុះជីវភាព ក៏មានមួយចំនួនដែរ ។

**រូបភាព ១: សុខមាលភាពបានរាយការណ៍ផ្ទាល់ខ្លួន ឆ្នាំ២០០២ និង ២០០៦**




*ប្រភព: អង្កេតរបស់CDRI -វិបសអ លើ ៥០៦គ្រួសារនៅខេត្តសៀមរាប នៅខែឧសភា ឆ្នាំ២០០៦*

យោងតាមអង្កេតគ្រួសារ មាន ២២% បានរាយការណ៍ថា សុខមាលភាពរបស់ពួកគេបានធ្លាក់ចុះ ជាពិសេសក្នុងចំណោមអ្នកក្រ ។ រឿងនេះបណ្តាលជាសំខាន់ពីកត្តាគ្រួសារ និងកត្តាសង្គម ដូចជា ការធ្លាក់ចុះចំណូលដោយសារការថយចុះចំនួនអ្នករកប្រាក់ចំណូល ជំងឺនិងវិបត្តិក្នុងគ្រួសារ កំនើនចំនួនសមាជិកគ្រួសារក្នុងបន្ទុក និងការឡើងថ្លៃទំនិញ ។ គ្រួសារទាំងនេះភាគច្រើន ស្ថិតក្នុងក្រុមរាយការណ៍ពីការធ្លាក់ចុះចំណូល ។

## **សន្និដ្ឋាន និងអនុសាសន៍**

កំនើនវិស័យទេសចរណ៍នៅខេត្តសៀមរាប មានផលប៉ះពាល់សេដ្ឋកិច្ចវិជ្ជមានទៅលើសហគមន៍មូលដ្ឋាន តាមរយៈការបង្កើតការងារ កំនើនប្រាក់ចំណូល និងការលើកកំពស់ជីវភាព ។ ប៉ុន្តែផលចំណេញពីវិស័យទេសចរណ៍ មិនបានបែងចែកស្មើភាពល្អទេក្នុងចំណោមក្រុមផ្សេងៗ ហើយវាមានភាពលំអៀងទៅខាងក្រុមអ្នកមិនក្រ ។ ជារឿយៗ អ្នកក្រតែងជួបប្រទះឧបសគ្គជាច្រើនក្នុងការទាញយកផលចំណេញឱ្យបានកាន់តែច្រើនពីវិស័យទេសចរណ៍ ដូចជាកង្វះខាតការអប់រំ ជំនាញ មូលធន វិបណ្ណាញសង្គម ព្រមទាំងមានរចនាសម្ព័ន្ធគ្រួសារទន់ខ្សោយ ។ ជាលទ្ធផល អ្នកក្រទទួលផលចំណេញមិនបានច្រើនដូចការរំពឹងទុកទេ ហើយការអភិវឌ្ឍន៍វិស័យទេសចរណ៍នៅខេត្តសៀមរាប ហាក់ដូចមិនទាន់អំណោយផលគ្រប់គ្រាន់ដល់អ្នកក្រនៅឡើយ ។

តាមការរកឃើញដូចខាងលើ គោលនយោបាយនិងយុទ្ធសាស្ត្រខាងទេសចរណ៍ ត្រូវផ្តោតមិនត្រឹមតែលើការជំរុញកំណើនទេសចរណ៍ប៉ុណ្ណោះទេ ប៉ុន្តែលើការបង្កើនផលចំណេញដល់អ្នកក្រផងដែរ ។ ដើម្បីបង្វែរផលចំណេញពីវិស័យទេសចរណ៍ឱ្យបានកាន់តែច្រើន ទៅកាន់សហគមន៍មូលដ្ឋាន និងអ្នកក្រ មានការផ្តល់អនុសាសន៍ ដូចតទៅ:

### *(១) ការបង្កើនប្រភេទទេសចរណ៍ទាក់ទាញភ្ញៀវ កន្លែងគោលដៅ និងសកម្មភាពទេសចរណ៍*

*ការបង្កើនប្រភេទទេសចរណ៍ និងកន្លែងគោលដៅទេសចរណ៍នៅតាមសហគមន៍ជនបទ:* កំណើនចំនួននៃទីកន្លែងគោលដៅទេសចរណ៍ អាចបង្កើនឱកាសឱ្យសហគមន៍មូលដ្ឋាន រួមទាំងអ្នកក្រផង បានចូលពាក់ព័ន្ធក្នុងសកម្មភាពទេសចរណ៍ និងបង្កើនការបែងចែកប្រាក់ចំនូលទៅដល់ពួកគេ ។ ភូមិព្រះដាក់ គឺជាឧទាហរណ៍ដ៏ល្អមួយនៃវិធីសាស្ត្រទេសចរណ៍បែបនេះ ដោយគេនាំអ្នកទេសចរទៅទស្សនាកន្លែងផលិតស្ករត្នោត នៅពេលធ្វើដំណើរទៅកាន់ប្រាសាទបន្ទាយស្រី ។ វត្តមានភ្ញៀវទេសចរបាននាំអោយមានអាជីវកម្មលក់វត្ថុអនុស្សាវរីយ៍ និងអាជីវកម្មតូចតាចផ្សេងទៀតកកើតឡើងនៅតាមបណ្តោយផ្លូវ ហើយកំរិតជីវភាពក៏បានប្រសើរឡើង ។

### *(២) ការបែងចែកសាជាថ្មីនៃផលចំណេញវិស័យទេសចរណ៍ដល់អ្នកក្រ*

វិធានការមួយទៀត ជាប់ពាក់ព័ន្ធនឹងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដែលអាចផ្តល់ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ដល់រដ្ឋាភិបាលជាតិ និងអាជ្ញាធរមូលដ្ឋាន ដើម្បីអនុវត្តការបែងចែកផលចំណេញឡើងវិញ ទៅអោយអ្នកក្រ ។ គោលនយោបាយពន្ធដារដ៏សមស្របនិងមានប្រសិទ្ធភាព អាចជាឧបករណ៍ដ៏ខ្លាំងក្លាសំរាប់បង្កើតនិងបង្កើនចំណូលពីវិស័យទេសចរណ៍ ។ ចំណូលមួយផ្នែកអាចយកទៅប្រើប្រាស់ដើម្បីរក្សាការពារទ្រព្យសកម្ម និងបរិស្ថានទេសចរណ៍ ហើយមួយផ្នែកទៀត អាចយកទៅប្រើប្រាស់ដើម្បីអនុវត្តវិធានការសំខាន់ៗមួយចំនួននៅក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ។ វិធានការទាំងនោះចាំបាច់ណាស់សំរាប់ជួយអ្នកក្រឱ្យចូលរួមបានកាន់តែខ្លាំងនៅក្នុង ដំណើរការអភិវឌ្ឍន៍វិស័យទេសចរណ៍ ។ វិធានការមានជាអាទិ ការអប់រំនិងការបណ្តុះបណ្តាលជំនាញដល់អ្នកក្រ ការថែទាំសុខភាព ទឹកស្អាត សេវាប្រសើរជាងមុនសំរាប់អ្នកក្រ ការកែលំអលទ្ធភាពឱ្យអ្នកក្របានចូលពាក់ព័ន្ធនឹងទីផ្សារទេសចរណ៍ ។ ឧទាហរណ៍ ថ្លៃចូលទស្សនាក្នុងឧទ្យានអង្គរមួយចំនែកធំថែមទៀត អាចយកទៅប្រើសំរាប់ផ្តល់ថវិកាដល់គំរោងនានាដែលមានលក្ខណៈអំណោយផលដល់អ្នកក្រ ។

ការអនុវត្តន៍ជាក់ស្តែងនៃវិធានការទាំងអស់ខាងលើ តំរូវអោយអង្គការទេសចរណ៍ ជាពិសេសក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍ខេត្ត មានធនធានមនុស្សគ្រប់គ្រាន់ មានសិទ្ធិអំណាចនិងការទទួលខុសត្រូវជាក់លាក់ក្នុងការធ្វើផែនការនិងសេចក្តីសំរេចចិត្ត និងមានឱកាសសំរាប់ការបង្កើតចំណូលពីវិស័យទេសចរណ៍ ។ ម្យ៉ាងទៀតក៏ត្រូវមានភាពជាដៃគូ ដ៏ជិតស្និទ្ធ និងការគាំទ្រជាបន្តបន្ទាប់ពីសហគមន៍អ្នកផ្តល់ជំនួយ អង្គការ មិនមែនរដ្ឋាភិបា

ាល វិស័យឯកជន ដើម្បីជំរុញកំណើនវិស័យទេសចរណ៍ និងពង្រឹងការបែងចែកផលចំណេញប្រកបដោយសមធម៌ទៅឱ្យអ្នកក្រ ។

**កំណត់សំគាល់**

១. ការប៉ាន់ស្មានរបស់ ក្រុមប្រឹក្សាទេសចរណ៍និងធ្វើដំណើរលើពិភពលោក ឆ្នាំ២០០៧ (World Travel & Tourism Council)

២. សៀវភៅស្ថិតិប្រចាំឆ្នាំ២០០៥ របស់វិទ្យាស្ថានជាតិស្ថិតិ

៣. ការគណនាតំលៃបន្ថែមដុលពីវិស័យទេសចរណ៍នៅឆ្នាំ២០០៤ គឺជាទិន្នន័យថ្មីបំផុតដែលអាចរកបាន ។

៤. ស្រទាប់សង្គមទាំងនេះ ត្រូវបានកំណត់ដោយ ក្រុមពិភាក្សាស្នូល (FGDs) ដែលជាទូទៅផ្អែកលើទំហំដី ប្រភេទផ្ទះ ការកាន់កាប់ទ្រព្យសកម្មធំៗ និងប្រភេទការងារ ។ ឧទាហរណ៍ "អ្នកក្រ" ត្រូវបានពិពណ៌នាជា គ្រួសារដែលគ្មាន រឺមានដីកសិកម្មតិចតួច និងខ្វះទ្រព្យសកម្មសំរាប់ធ្វើកសិកម្ម ហើយផលិតស្រូវមិនបានគ្រប់គ្រាន់សំរាប់ការបរិភោគក្នុងគ្រួសារទេ ។ អ្នកក្រ ក៏សំដៅដល់អ្នកមានមុខរបរផ្តល់ប្រាក់ចំណូលទាប ដូចជា អ្នកស៊ីឈ្នួលធ្វើស្រែ កម្មករសំណង់គ្មានជំនាញ អ្នកបោសសំអាត អ្នកយាមនៅតាមប្រាសាទ និងសណ្ឋាគារ អ្នកលក់ដូរតូចតាច និងអ្នករើសអេតចាយ ។

៥. សហគមន៍នៅជិត សំដៅដល់ សហគមន៍ដែលស្ថិតនៅចំងាយជាមធ្យម ៨គីឡូម៉ែត្រ ពីក្រុងសៀមរាប រឺតំបន់ប្រាសាទ រីឯសហគមន៍នៅឆ្ងាយ

---

*តពីទំព័រ ៣* **បញ្ហាប្រឈមនៃ...**

អនុវត្តន៍ជាក់ស្តែង នៅក្នុងការងារស្រោចស្រព វិធីសាស្ត្រនេះបង្កបញ្ហាមួយចំនួន ដោយសារទឹកជាធនធានធម្មជាតិ សេដ្ឋកិច្ច និងនយោបាលដ៏ស្មុគស្មាញ ហើយប្រជាជនកម្ពុជាពុំមានទំលាប់បង់ថ្លៃប្រើទឹកទេ ។

ដើម្បីបង្កើនឆន្ទៈបង់ថ្លៃប្រើទឹក មានកត្តាបីត្រូវពិចារណា: (១) ថ្លៃទឹកត្រូវកំនត់តាំងពីដំបូងឱ្យមានលក្ខណៈប្រាកដនិយម សមស្របតាមតំបន់មុខសញ្ញា ហើយត្រូវបង្កើនជាបណ្តើរៗឱ្យដល់កំរិតនៃថ្លៃដើមប្រតិបត្តិការ និងការថែទាំជួសជុល (២) សំខាន់ត្រូវធ្វើយ៉ាងណាឱ្យកសិករបានយល់ដឹងពីចំណងទាក់ទងរវាងថ្លៃប្រើទឹក និងប្រតិបត្តិការនិងការថែទាំជួសជុល និង (៣) គួរធ្វើការវិភាគចំណាយនិងផលចំណេញយ៉ាងសាមញ្ញ ដើម្បីជួយកសិករអោយមើលឃើញនូវផលចំណេញសមរម្យមួយ ។ ម្យ៉ាងទៀត ត្រូវបង្កើនផលិតភាពផលដំណាំ ដោយផ្តល់សេវាគាំទ្រមួយចំនួន ដូចជា ឥណទាន ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម បច្ចេកវិទ្យាថ្មីៗ និងលទ្ធភាពទទួលបានធាតុចូលកសិកម្ម ផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជន ។

**បញ្ហាទាក់ទងនឹងដែនរងទឹកភ្លៀង**

ពាក្យ *ទីជំរាល* សំដៅដល់ " ផ្ទៃដីមួយកន្លែងដែលមានទឹកហូរចុះតាមជំរាលតាមរយៈបណ្តាញផ្លូវទឹកនានា ទាំងនៅក្រោមដី និងលើផ្ទៃដី ។ ជាទូទៅ ផ្លូវទឹកទាំងនេះវាមកជួបគ្នាបង្កើតជា អូរ និងស្ទឹង ដែលរីកកាន់តែធំឡើង នៅពេលទឹកហូរចុះកាន់តែបានឆ្ងាយ ហើយទីបំផុតទៅដល់មាត់ពាម និងសមុទ្រ ។ ទីជំរាលអាចធំនិងតូច ។ អូរ ស្ទឹង រឺទន្លេនីមួយៗ តែងមានទីជំរាលផ្ទាល់មួយ និងទីជំរាលតូចៗច្រើនដែលតភ្ជាប់គ្នាបង្កើតជា ទីជំរាលធំៗ" ។ ផលប៉ះពាល់នៃសកម្មភាពផ្សេងៗក្នុងដែនរងទឹកភ្លៀង ទៅលើលំហូរទឹកស្ទឹង និងគុណភាពទឹក គឺជាចំណុចដ៏សំខាន់សំរាប់ការស្រាវជ្រាវ ។ ការបាត់បង់ព្រៃឈើ និងសកម្មភាពអភិវឌ្ឍន៍ឯទៀត (ដូចជា អាជីវកម្មយករ៉ែ) នៅតំបន់ខាងលើខ្សែទឹក វាបង្កបញ្ហាទាំងនៅខាងលើខ្សែទឹក និងខាងក្រោមខ្សែទឹក ។ បញ្ហាដែលអាចកើតមាននិងត្រូវយកចិត្តទុកដាក់ គឺការហូរច្រោះដី ការដុះដីល្បប់ ផលវិបាកខាងអេកូឡូស៊ីនៃការផ្លាស់ប្តូររបបទឹកហូរ ផលប៉ះពាល់ទៅលើការនេសាទនិងជលវប្បកម្ម ។ល។ ការសិក្សាស៊ីជំរៅលើដែនរងទឹកភ្លៀងនឹងផ្តល់ព័ត៌មាន និងទិន្នន័យដ៏ចាំបាច់សំរាប់វិភាគពីចំណាយនិងផលចំណេញនៃគំរោងអភិវឌ្ឍន៍នាពេលអនាគត ។

ការប្រើប្រាស់ដីនិងទឹក មានផលប៉ះពាល់ដោយផ្ទាល់ទៅលើលំហូរទឹក ការដុះដីល្បប់ និងសារធាតុបំប៉ន ដែលរួមចំណែកដល់បំរែបំរួលប្រព័ន្ធជលផលនៅតំបន់ខាងក្រោមខ្សែទឹក ។ ការគ្រប់គ្រងទីជំរាល មិនមែនធ្វើត្រឹមតែលើកត្តារូបវន្តនានាប៉ុណ្ណោះទេ ពីព្រោះកន្លងមកគេឃើញថា ការដាក់អនុវត្តនូវវិទ្យាសាស្ត្រសង្គម បរិស្ថាន និងសេដ្ឋកិច្ច គឺមានសារៈសំខាន់បំផុត ។ ដើម្បីលើកកំពស់ការគ្រប់គ្រងប្រកបដោយចីរភាព គេត្រូវដោះស្រាយបញ្ហាគ្រប់គ្រងទឹកដ៏ស្មុគស្មាញមួយចំនួន ក្នុងចំណោមប្រជាជនស្ថិតក្នុងស្រទាប់សង្គមខុសៗគ្នា និងមានតំលៃសីលធម៌ខុសៗគ្នា និងត្រូវទាញយកបទ ពិសោធន៍ពីខាងក្រៅ ។ ដំណើរការសំរេចចិត្ត មិនត្រូវគិតគូរតែពីបញ្ហារូបវ័ន្ត និងអេកូឡូស៊ីប៉ុណ្ណោះទេ ប៉ុន្តែត្រូវពិចារណាផងដែរពីផលប្រយោជន៍ខាង សេដ្ឋកិច្ច-សង្គមកិច្ច និងបន្ទុកចំណាយលើសកម្មភាពជាជំរើសផ្សេងៗទៀត ដែរគេអាចអនុវត្តបាន ។

**សេចក្តីសន្និដ្ឋាន**

ភាពស្មុគស្មាញនៃការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ប្រែប្រួលខុសគ្នាទៅតាមទំហំប្រព័ន្ធ ។ ប្រព័ន្ធធំៗ មានផលប៉ះពាល់ធំជាង ទាំងលើចំនួនផ្ទៃដីស្រោចស្រព និងចំនួនគ្រួសារអ្នកទទួលផល ប៉ុន្តែវាទាមទារទុនវិនិយោគច្រើន និងសមត្ថភាពខាងអភិបាលកិច្ចខ្ពស់ ។ អភិបាលកិច្ចទឹកសំរាប់ប្រព័ន្ធគ្រប់ខ្នាត វាផ្សារភ្ជាប់នឹងការរចនារៀបចំខាងបច្ចេកទេស ការរៀបចំនិងសមត្ថភាពខាងស្ថាប័នក្នុងកិច្ចដំណើរការ និងថែទាំប្រព័ន្ធ ។ ប្រព័ន្ធដែលរចនារៀបចំបានល្អ នាំឱ្យមានប្រសិទ្ធភាពខ្ពស់ក្នុងការប្រើប្រាស់ទឹក ដែលជួយបង្កើនផលិតកម្មកសិកម្ម និងការចូលរួមពីប្រជាជន ។ ការរៀបចំស្ថាប័នសមស្របល្អគួរតំណាងអោយសហគមន៍ផ្សេងៗទាំងអស់ដែលប្រើប្រាស់ធនធានទឹករួមគ្នា ដើម្បីដោះស្រាយបញ្ហាប្រើប្រាស់ទឹកហួសកំរិត ទាំងនៅក្នុង និងឆ្លងកាត់ព្រំដែនសហគមន៍ ។ កិច្ចដំណើរការ និងការថែទាំប្រព័ន្ធ វាអាស្រ័យលើ សមត្ថភាពបំពេញមុខងាររបស់អង្គការចាត់តាំងតាមបែបវិមជ្ឈការ ហើយសមាជិកនៃអង្គការនេះគួរតែជ្រើសតាំងឡើងតាមការបោះឆ្នោតដោយសេរី និងយុត្តិធម៌ មានផលប្រយោជន៍រួមគ្នា និងធ្វើការដោយឯករាជ្យគ្មានការជ្រៀតជ្រែកខាងនយោបាយ ។

នៅប្រទេសកម្ពុជា ការគ្រប់គ្រងទីជំរាលជាគោលគំនិតថ្មីមួយ ហើយសព្វថ្ងៃមានបទពិសោធន៍តិចនៅឡើយ ពាក់ព័ន្ធនឹងទំរង់នៃការគ្រប់គ្រងចំរុះបញ្ចូលគ្នានេះ ដែលបង្កឱ្យមានការលំបាកជាច្រើននៅពេលគេយកគំនិតផ្តួចផ្តើមនេះទៅអនុវត្ត និងរៀបចំជាផែនការ ។ ដូច្នេះ គេពិតជាត្រូវការចងក្រងជាឯកសារនូវបទពិសោធន៍ និងមេរៀនដែលរៀនសូត្របាន ព្រមទាំងកសាង

# ការវិភាគផលប៉ះពាល់សេដ្ឋកិច្ចនៃប្រាក់កំរៃតាមព្រំដែនលើផលិតកម្មពោតនៅភាគខាងលិចកម្ពុជា

*លោក នូ កែវសុទ្ធា បរិយាយពីសក្តានុពលដើម្បីអភិវឌ្ឍន៍ផលិតផលពោត និងពិនិត្យពីសារសំខាន់នៃប្រាក់កំរៃឆ្លងកាត់ព្រំដែនលើប្រសិទ្ធភាពថ្លៃ**

កសិកម្មកម្ពុជាតំណាងឱ្យជិត ៣០% នៃ ផសស ហើយវិស័យកាត់ដេរ ទេសចរណ៍ និងសេវាកម្ម តំណាងឱ្យចំនួនដែលនៅសល់ ។ នាបច្ចុប្បន្ន តំបន់ដាំដុះមានប្រហែល ៣៦.០០០គីឡូម៉ែត្រការ៉េ ដែលស្មើនឹង ២០% នៃផ្ទៃដី សរុបនៅកម្ពុជា ។ ផលិតផលកសិកម្មសំខាន់ៗរួមមាន ស្រូវ កៅស៊ូ ពោត សណ្តែកសៀង អំពៅ ដំឡូងមី ចេក ឈើហ៊ុប និងផលិតផលសមុទ្រ ។

កម្ពុជាមានសក្តានុពល ក្នុងការអភិវឌ្ឍន៍ដំណាំសណ្តែកសៀង និងពោត ដោយផ្អែកលើទីតាំងភូមិសាស្ត្រ ដីមានជីជាតិ និងដីសល់ទំនេរ ។ សក្តានុពលនេះ មានការទទួលស្គាល់ និងចាត់ទុកជាអទិភាពមួយនៅក្នុងឯកសារគំរោងផែនការជាតិសំខាន់ៗ ដូចជា ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច លើកទី២ ឆ្នាំ២០០១-០៥ និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ឆ្នាំ២០០២-០៤ ។ ក្នុងការប្រកួតប្រជែងថ្លៃ កម្ពុជាទំនងជាមានឧត្តមភាពប្រៀបធៀបចំពោះផលិតផលសណ្តែកសៀង និងពោត ធៀបទៅនឹងប្រទេសថៃ និងវៀតណាម (Nou 2005) ។

ទោះជាយ៉ាងនេះក្តី សក្តានុពលនេះមិនទាន់លេចជារូបរាងទេ ដោយសារមានកំហិតលើផលិតកម្ម និងម៉ាឃីតទីងច្រើនពេក ។ កំហិតផលិតកម្ម មានដូចជាកង្វះគ្រាប់ពូជមានគុណភាព បច្ចេកវិទ្យា ព័ត៌មាន និងឥណទាន ។ កំហិតផ្នែកម៉ាឃីតទីង រួមមាន កង្វះព័ត៌មានទីផ្សារ ថ្លៃដើមនិងសោហ៊ុយដឹកជញ្ជូនខ្ពស់ ហើយនិងការខ្វះខាតទំនាក់ទំនងនិងការមិនទុកចិត្តគ្នា រវាងកសិករ និងអ្នកទិញ ។ ផលិតផលកសិកម្មនាំចេញ ភាគច្រើនគឺជាផលិតផលមិនទាន់កែច្នៃ ពីព្រោះកម្ពុជាមានសមត្ថភាពកែច្នៃផលកសិកម្មតិចតួច និងការនាំចេញមានលក្ខណៈក្រៅផ្លូវការ[១] និងត្រូវបង់កំរៃក្រៅផ្លូវការខ្ពស់[២] នៅតាមព្រំដែន ។ អត្ថបទនេះ មានគោលដៅធ្វើការវិភាគលើផលប៉ះពាល់សេដ្ឋកិច្ចចំពោះប្រាក់កំរៃតាមព្រំដែន ទាំងនៅកំរិតប្រមូលផ្តុំ (ការមិនបាន នាំចេញ ការបាត់បង់ប្រាក់ចំណូលសរុប) និងនៅកំរិតបុគ្គល (ការបាត់បង់ប្រាក់ចំណូលសុទ្ធនៅតាមកសិដ្ឋាន) នៅភាគខាងលិចកម្ពុជា ។

**ផលិតកម្មពោតនៅភាគខាងលិចកម្ពុជា**

ខេត្តបន្ទាយមានជ័យ (ម៉ាល័យ) បាត់ដំបង និងក្រុងប៉ៃលិន ជាតំបន់ផលិតកម្មពោតនៅភាគខាងលិចកម្ពុជា ។ តារាង១ ដល់ ៣ សង្ខេបពីផ្ទៃដីប្រមូលផលផលិតកម្ម និងទិន្នផលនៅតំបន់ទាំងនេះ ក្នុងប៉ុន្មានឆ្នាំកន្លងមក ។

**តារាង១ : តំបន់ប្រមូលផលពោតនៅភាគខាងលិចកម្ពុជា ២០០២-០៥**

| ភាគខាងលិចកម្ពុជា | ផ្ទៃដីប្រមូលផល (ហិកតា) | | | | |
|---|---|---|---|---|---|
| | 2002 | 2003 | 2004 | 2005 | មធ្យម |
| បាត់ដំបង | 32,409 | 43,126 | 35,874 | 39,233 | **37,661** |
| ប៉ៃលិន | 1,611 | 4,301 | 9,647 | 16,653 | **8,053** |
| បន្ទាយមានជ័យ | 8,435 | 7,745 | 4,647 | 3,167 | **5,999** |
| **សរុប** | **42,455** | **55,172** | **50,168** | **59,053** | **51,712** |

*ប្រភព: ក្រសួងកសិកម្ម, ស្ថិតិកសិកម្ម ២០០២-០៥*

**តារាង២ : ផលិតកម្មពោតនៅភាគខាងលិចកម្ពុជា ២០០២-០៥**

| ភាគខាងលិចកម្ពុជា | ផលិតកម្ម (តោន) | | | | |
|---|---|---|---|---|---|
| | 2002 | 2003 | 2004 | 2005 | មធ្យម |
| បាត់ដំបង | 92,778 | 236,295 | 155,030 | 108,018 | **148,030** |
| ប៉ៃលិន | 4,833 | 17,204 | 43,354 | 66,606 | **32,999** |
| បន្ទាយមានជ័យ | 9,329 | 15,133 | 10,489 | 9,554 | **11,126** |
| **សរុប** | **106,940** | **268,632** | **208,873** | **184,178** | **192,156** |

*ប្រភព: ក្រសួងកសិកម្ម, ស្ថិតិកសិកម្ម ២០០២-០៥*

**តារាង៣ : ទិន្នផលពោតនៅភាគខាងលិចកម្ពុជា ២០០២-០៥**

| ភាគខាងលិចកម្ពុជា | ផលិតកម្ម (តោន/ហិកតា) | | | | |
|---|---|---|---|---|---|
| | 2002 | 2003 | 2004 | 2005 | មធ្យម |
| បាត់ដំបង | 2.86 | 5.48 | 4.32 | 2.75 | **3.85** |
| ប៉ៃលិន | 3.00 | 4.00 | 4.50 | 4.00 | **3.87** |
| បន្ទាយមានជ័យ | 1.11 | 1.95 | 2.26 | 3.02 | **2.08** |
| **សរុប** | **2.52** | **4.87** | **4.16** | **3.12** | **3.67** |

*ប្រភព: ក្រសួងកសិកម្ម, ស្ថិតិកសិកម្ម ២០០២-០៥*

ទោះបីជាតួលេខបង្ហាញក្នុងតារាង១-៣ បានមកពីទិន្នន័យផ្លូវការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប៉ុន្តែមានការផ្តល់មតិថា ទិន្នន័យ នេះ បានប៉ាន់ប្រមាណទាបពេកពីផលិតកម្មពោតនៅភាគខាងលិចកម្ពុជា ។ អង្កេតនៅថ្នាក់ឃុំ បានផ្តល់នូវការប៉ាន់ស្មានខុសគ្នា និងខ្ពស់ជាងយ៉ាងខ្លាំង នៃទិន្នផលពោត (មើលតារាង៤ ខ្ទង់ទី៥ ខាងក្រោម) ។

ដំណាំពោតដាំដោយគ្រួសារប្រហែល ១១% នៅក្នុងតំបន់ចំនួន ៣ នៅភាគខាងលិចកម្ពុជា ។ ទោះជាយ៉ាងនេះក្តី ដូចបង្ហាញក្នុងតារាង៤ តួលេខភាគរយក្នុងតំបន់ជុំវិញក្រុងប៉ៃលិន (៧៣%) មានកំរិតខ្ពស់ជាខ្លាំងធៀបនឹងខេត្តបាត់ដំបង (៩%) រឺខេត្តបន្ទាយមានជ័យ (៨%) ។

ដើម្បីប៉ាន់ស្មានពីទំហំនៃប្រាក់កំរៃនៅតាមព្រំដែន ចំពោះគ្រួសារកសិករដែលពឹងផ្អែកលើការដាំពោតសំរាប់លក់ គេចាំបាច់ត្រូវប៉ាន់ស្មានពីប្រាក់ចំណូលសុទ្ធក្នុងមួយហិកតា ។ តួលេខប៉ាន់ស្មាននៃប្រាក់ចំណូលពីផលិតកម្មពោត គឺទទួលបានពីអង្កេតថ្មីៗនៅខេត្តបាត់ដំបង ។ លទ្ធផលមានចុះសង្ខេបក្នុងតារាង៥ ខាងក្រោម ។

* អត្ថបទនេះ ផ្អែកលើគំរោងស្រាវជ្រាវឈ្មោះថា "ការកែលំអប្រព័ន្ធម៉ាឃីតទីងសំរាប់ផលិតផលពោត និងសណ្តែកសៀងនៅកម្ពុជា" ឧបត្ថម្ភដោយ ACIAR ។ ការរកឃើញក្នុងអត្ថបទនេះ មានបទបង្ហាញ និងការយល់ព្រមនៅឯសិក្ខាសាលាមួយស្តីពី ការកែលំអប្រព័ន្ធម៉ាឃីតទីងសំរាប់ផលិតផលពោតនៅភាគខាងលិចកម្ពុជា (សភាពាណិជ្ជកម្មខេត្តបាត់ដំបង នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៦) ។ លោក នូ កែវសុទ្ធា ជាអ្នកស្រាវជ្រាវនៅ CDRI-វបសអ ហើយបច្ចុប្បន្ន កំពុងបន្តការសិក្សាថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យ Canberra ប្រទេសអូស្ត្រាលី ។

**តារាង ៤: គ្រួសារផលិតពោត និងទិន្នផលជាមធ្យម**

| ភាគខាងលិចកម្ពុជា | ចំនួនគ្រួសារសរុប | គ្រួសារផលិតពោត* | ចំណែកនៃ គ្រួសារផលិតពោត (%) | ទិន្នផលជាមធ្យម* (តោន/ហិកតា) |
|---|---|---|---|---|
| បាត់ដំបង | 163,734 | 14,946 | 9.1 | 3 - 5 |
| ប៉ៃលិន | 10,331 | 7,496 | 72.6 | 4 - 6 |
| បន្ទាយមានជ័យ | 123,917 | 9,471 | 7.6 | 2 - 3 |
| **សរុប** | 297,982 | 31,913 | 10.7 | - |

** ទិន្នន័យអាស្រ័យលើការប៉ាន់ប្រមាណរបស់មេឃុំ*

**តារាង៥: ថ្លៃដើមផលិតកម្ម និងប្រាក់ចំណូលពីដំណាំពោតក្នុងមួយហិកតា នៅខេត្តបាត់ដំបង**

| ចំណូល និងចំណាយ | តំលៃ (ដុល្លារUS/ហិកតា) |
|---|---|
| ចំណាយ | |
| ថ្លៃជួលដី | 30.0 |
| គ្រាប់ពូជ | 33.6 |
| ការរៀបចំដី | 40.0 |
| ការដាំ | 5.0 |
| ដី | - |
| ថ្នាំកំចាត់សត្វល្អិត | - |
| ថ្នាំកំចាត់ស្មៅ | 10.0 |
| ការស្រោចស្រព | - |
| ការប្រមូលផល | 20.76 |
| ផ្សេងៗ | - |
| **ថ្លៃដើមសរុប** | **139.36** |
| **ចំណូល (៣.៥ តោន/ហិកតា)** | **175.00** |
| **ប្រាក់ចំណូលសុទ្ធ** | **35.64** |

*ប្រភព: នូ កែវសុទ្ធា អង្កេត២០០៦*

តារាង៥ បង្ហាញថា ប្រាក់ចំណូលសុទ្ធជាមធ្យមក្នុងមួយហិកតា មានតួលេខប៉ាន់ស្មានដល់ទៅ ៣៥.៦៤ដុល្លារ ។ ក្នុងនេះមានប៉ូកទាំងប្រាក់កំរៃផង ។

**ប្រព័ន្ធចែកចាយសំខាន់ៗនៃផលិតផលពោតនៅភាគខាងលិចកម្ពុជា**

ប្រហែល៩៥% នៃផលិតកម្មពោតនៅភាគខាងលិចកម្ពុជា បាននាំចេញទៅថៃ ។ ចំនួននៅសល់ទុកសំរាប់ប្រើប្រាស់ក្នុងស្រុក ជាសំខាន់សំរាប់ក្រុមហ៊ុន CP នៅភ្នំពេញ រឺនៅឆ្នាំខ្លះបាននាំចេញទៅវៀតណាម ។ ការដឹកជញ្ជូនទៅវៀតណាមច្រើនតែមានទំហំតូចដោយសារតែចំងាយឆ្ងាយ និងផ្លូវមិនល្អ ជាពិសេសនៅភាគខាងលិចកម្ពុជា ។ មានពាណិជ្ជករ ៤ថ្នាក់ ដែលពាក់ព័ន្ធនឹងការនាំចេញពោតពីភាគខាងលិចកម្ពុជាទៅដល់ថៃ គឺមាន អ្នកប្រមូលទិញ អ្នកលក់ដុំ អ្នកទិញស្តុក រឺអ្នកសំងួតតូចតាច និងពាណិជ្ជករថៃ (រូបទី ១) ។

**ប្រាក់កំរៃលើការនាំចេញពោតនៅពីភាគលិចកម្ពុជាទៅថៃ**

ពោតនៅភាគខាងលិចកម្ពុជា គេនាំចេញជាសំខាន់ទៅប្រទេសថៃ ដោយកាត់តាមខេត្តបាត់ដំបង និងក្រុងប៉ៃលិន ។ ពោតដែលដាំដុះនៅម៉ាល័យក្នុងខេត្ត បន្ទាយមានជ័យ ក៏នាំចេញកាត់តាមខេត្តបាត់ដំបងដែរ ។ តារាង៦ និង ៧ បង្ហាញពីប្រាក់កំរៃដែលយកពីពាណិជ្ជករ សំរាប់ការនាំចេញពោតពីភាគខាងលិចកម្ពុជាទៅប្រទេសថៃ ។

ប្រាក់កំរៃនៅតាមព្រំដែនទាំងនេះនៅតែកើតមាន ទោះជាមានកិច្ចព្រមព្រៀង AISP (ប្រព័ន្ធអនុគ្រោះសមាហរណកម្មអាស៊ាន) ដែលបានចុះហត្ថលេខានៅឆ្នាំ២០០៣ រវាងថៃ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ប្រ៊ុយនេ និងវៀតណាម ។ នៅក្រោមកិច្ចព្រមព្រៀង AISP ពុំមានយកពន្ធលើការនាំចេញផលិតផលកសិកម្មពីកម្ពុជាទៅប្រទេសទាំងនេះទេ គឺមានតែប្រាក់កំរៃរដ្ឋបាលប៉ុណ្ណោះ ដែលប្រមូលយកដោយក្រសួងពាណិជ្ជកម្ម យោងលើលិខិតអនុញ្ញាតរបស់ AISP ។ ទោះបីជាក្រុមហ៊ុននាំចេញ មានលិខិតអនុញ្ញាតរបស់ AISP ក្តី ក៏ពួកគេចាំបាច់ត្រូវបង់ប្រាក់កំរៃទៅឱ្យអាជ្ញាធរព្រំដែនកម្ពុជា និងថៃ តាមកំរិតប្រហាក់ប្រហែលនឹងតួលេខ ដូចបង្ហាញក្នុងតារាង៦ និង ៧ ។ អ្នកនាំចេញម្នាក់បានរាយការណ៍ថា គាត់មិនបានទទួលផលប្រយោជន៍អ្វីទេពី AISP ។ ជាការពិតណាស់ នៅពេលដែលក្រុមហ៊ុនបានចុះបញ្ជីដើម្បីស៊ីវិញ្ញាបនប័ត្រពី AISP ក្រុមហ៊ុនក៏ត្រូវបង់ពន្ធលើប្រាក់ចំណូល (១%) និងពន្ធលើប្រាក់ចំណេញ (១០%) ។ និយាយដោយខ្លីមក មានក្រុមហ៊ុនខ្លះមិនបានចុះបញ្ជីដើម្បីស៊ីវិញ្ញាបនប័ត្រ AISP ទេ ហើយថែមទាំង មិនបានបង់ពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់ចំណេញទៀត ។

**រូបទី ១: ប្រព័ន្ធម៉ាឃីតទីងនៃពោត និងសណ្តែកសៀង នៅភាគខាងលិចកម្ពុជា**



តារាង ៦: ថ្លៃសេវាដឹកជញ្ជូនពោតពីឃុំកំរៀង នៅខេត្តបាត់ដំបងទៅថៃ (ប្រហែល៣០ គីឡូម៉ែត្រពីព្រំដែន) ឆ្នាំ២០០៥

| មុខចំណាយ | ដុល្លារUS/តោន | ចំណែកសរុប (%) |
|---|---|---|
| **ប្រាក់កំរៃសរុបនៅខាងដីកម្ពុជា** | **3.70** | **45.8** |
| ប្រាក់កំរៃតាមផ្លូវ (៣០-៤០បាតនៅកន្លែងនីមួយៗ) | 0.24 | 3.0 |
| ប្រាក់កំរៃកំណត់ទៅលើរថយន្តធំៗ | 0.48 | 5.9 |
| ភាស៊ីនៅព្រំដែនខាងដីកម្ពុជា * | 2.38 | 29.5 |
| ប្រាក់កំរៃសំរាប់ប៉ូលីសព្រំដែន | 0.24 | 3.0 |
| ពន្ធផ្លូវសំរាប់អាជ្ញាធរដឹកជញ្ជូន | 0.36 | 4.5 |
| **ភាស៊ីនៅព្រំដែនខាងដីថៃ **** | **4.37** | **54.2** |
| **ប្រាក់កំរៃសរុប** | **8.07** | **100.0** |

* ការបែងចែកភាស៊ី នៅព្រំដែនខាងដីកម្ពុជា នេះមិនច្បាស់លាស់ទេ ប៉ុន្តែគេជឿថាសំរាប់: ថ្លៃរដ្ឋបាល ថ្លៃអន្តោប្រវេសន៍ ប៉ូលីសកម្ពុជានៅតាមព្រំដែន ទាហានព្រំដែន ឃុំ/សង្កាត់នៅតាមព្រំដែន ខេត្តបាត់ដំបង និងក្រសួងពាណិជ្ជកម្ម ។ វាដំណាងឱ្យ ៤៦% នៃប្រាក់កំរៃសរុប ។

** ការបែងចែកថ្លៃភាស៊ី នៅព្រំដែនថៃ គឺសំរាប់ប្រាក់កំរៃរដ្ឋបាល ពន្ធគយ ប៉ូលីសនៅព្រំដែន ទាហ៊ានតាមព្រំដែន និងឃុំនៅព្រំដែន ។ វាមានចំនួន ៥៤%នៃប្រាក់កំរៃទាំងអស់ ។

*ប្រភព:* Nou 2005

## ផលប៉ះពាល់សេដ្ឋកិច្ចនៃប្រាក់កំរៃនៅតាមព្រំដែន នៅកំរិតសរុប និងបុគ្គល

តារាង៨ និង៩ ផ្តល់ការប៉ាន់ស្មានពីផលប៉ះពាល់សេដ្ឋកិច្ចនៃប្រាក់កំរៃនៅតាមព្រំដែនទាំងនៅកំរិតសរុប និងបុគ្គល ។ ក្នុងការគណនានេះ គេសន្មតថា ផលប៉ះពាល់នៃប្រាក់កំរៃនៅតាមព្រំដែន ត្រូវជះទៅដល់កំរិតកសិដ្ឋាន ពីព្រោះកសិករ គឺជាអ្នកត្រូវទទួលយកក្រោយគេនូវប្រាក់ចំណូលសុទ្ធ ដែលប្រព័ន្ធផ្គត់ផ្គង់ប្រមូលយកបាន ។ ប្រាក់ចំណូលរបស់កសិករ គឺជាអ្វីដែលនៅសល់បន្ទាប់ពីកាត់កងបន្ទុកចំណាយទាំងអស់នៃខ្សែចង្វាក់ផ្គត់ផ្គង់ (រួមទាំងប្រាក់កំរៃនៅតាមព្រំដែន) ។ គេសន្មតថា អ្នកចូលរួមផ្សេងៗទៀតក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ អនុវត្តតាមមូលដ្ឋានថ្លៃដើមបូកអត្រាចំណេញ ។ តារាង៨ ចាប់ផ្តើមពីផលិតកម្មសរុបដែលបានប៉ាន់ស្មានក្នុងតំបន់ដាំដុះពោតនីមួយៗ នៅភាគខាងលិចកម្ពុជាសំរាប់ឆ្នាំ២០០៥ ដោយប្រើទិន្នន័យក្នុងតារាង ២ ។

តារាង ៧: ប្រាក់កំរៃដឹកជញ្ជូនពោត ពីក្រុងប៉ៃលិនទៅថៃ

| មុខចំណាយ | ដុល្លារUS/តោន | ចំណែកសរុប (%) |
|---|---|---|
| ***ប្រាក់កំរៃសរុបនៅព្រំដែនកម្ពុជា*** | **2.07** | **43.4** |
| ប៉ូលីសអន្តរជាតិ | 0.36 | 7.5 |
| គយ | 0.54 | 11.3 |
| កាំកុងត្រូល | 0.18 | 3.8 |
| ប៉ូលីសសេដ្ឋកិច្ច | 0.09 | 1.9 |
| ទាហ៊ាន | 0.09 | 1.9 |
| អាជ្ញាធរព្រំដែន | 0.36 | 7.5 |
| ប៉ូលីសយោធា | 0.09 | 1.9 |
| កន្លែងសំរួលនៃព្រំដែនទ្វេភាគី | 0.36 | 7.5 |
| ***ប្រាក់កំរៃសរុបនៅព្រំដែនថៃ*** | **2.70** | **56.6** |
| **ប្រាក់កំរៃសរុប** | **4.77** | **100.0** |

ផលិតកម្មសរុបនេះ គេយកមកគុណនឹង ៩៥%[៤] (ភាគរយការនាំចេញ) ដើម្បីគណនាតួលេខប៉ាន់ស្មាននៃការនាំចេញសរុប ។ តួលេខប៉ាន់ស្មានការនាំចេញនេះ បន្ទាប់មកគេយកទៅគុណជាមួយនឹងប្រាក់កំរៃនៅតាមព្រំដែនបានប៉ាន់ស្មានក្នុងតារាង៦ និង ៧ ដើម្បីទទួលបានប្រាក់កំរៃតាមព្រំដែនសរុបដែលគេប៉ាន់ថាប្រហែលជា ១,២លានដុល្លារ/ឆ្នាំ ។ តួលេខប្រាក់កំរៃសំរាប់ការនាំចេញសរុប ត្រូវចែកនឹងចំនួនគ្រួសារកសិករដាំដុះពោត (តារាង៤) ដើម្បីទទួលបានបន្ទុកចំណាយប៉ាន់ស្មាននៃប្រាក់កំរៃនៅតាមព្រំដែន សំរាប់កសិដ្ឋានជាមធ្យមក្នុងតំបន់នីមួយៗ ។

គេអាចយល់ដឹងកាន់តែច្បាស់ថែមទៀត បើសិនមានការប៉ាន់ស្មានពីផលប៉ះពាល់នៃប្រាក់កំរៃនៅតាមព្រំដែនលើដីក្នុងមួយហិកតា ដូចបង្ហាញក្នុងតារាង ៩ ។ ចំណូលសុទ្ធក្នុងមួយហិកតាបានប៉ាន់ស្មាននៅប៉ៃលិន និងបាត់ដំបង រឺបន្ទាយមានជ័យ បានបង្ហាញក្នុងខ្ទង់ទី២ ។ តួលេខទាំងនេះគឺមានបូកបញ្ចូលទាំងឥទ្ធិពលនៃប្រាក់កំរៃនៅព្រំដែនផង ។ ខ្ទង់ទី៣ បង្ហាញពីប្រាក់កំរៃនៅតាម ព្រំដែនបានប៉ានស្មាន ចេញពីតារាង ៦ និង ៧ ។ តួលេខប៉ាន់ស្មានប្រាក់កំរៃ ក្នុងមួយតោន ត្រូវយកទៅគុណជាមួយទិន្នផលប៉ាន់ស្មានក្នុងមួយហិកតា ដើម្បី ទទួលបានប្រាក់កំរៃនៅតាមព្រំដែនប៉ាន់ស្មានក្នុងមួយហិកតាក្នុងខ្ទង់ទី៤ ។ ខ្ទង់ទី៥ តំណាងឱ្យការផ្លាស់ប្តូរប៉ាន់ស្មាននៃប្រាក់ចំណូលសុទ្ធក្នុងមួយហិកតា ដោយ ដកប្រាក់កំរៃតាមព្រំដែនក្នុងមួយហិកតា ចេញពីចំណូលសុទ្ធក្នុងមួយហិកតា ។

តារាង៩ ខ្ទង់ទី៥ បង្ហាញថា ប្រាក់កំរៃនៅតាមព្រំដែនមានផលប៉ះពាល់យ៉ាងខ្លាំងលើប្រាក់ចំណូលសុទ្ធនៃផលិតកម្មពោតជាលក្ខណៈពាណិជ្ជកម្ម ។មានការប៉ាន់ស្មានថា នៅប៉ៃលិន ប្រាក់ចំណូលសុទ្ធក្នុងមួយហិកតានឹងកើន ដល់ប្រហែល ៤៤% រីឯនៅបាត់ដំបង និងបន្ទាយមានជ័យ ប្រាក់ចំណូលសុទ្ធ នឹងកើនដល់ទៅ ៨០% បើសិនគ្មានប្រាក់កំរៃនៅតាមព្រំដែនទេ ។

## សន្និដ្ឋាន

ផ្អែកលើការស្រាវជ្រាវនិងការវិភាគខាងលើ ប្រាក់កំរៃនៅតាមព្រំដែនមានផលប៉ះពាល់សេដ្ឋកិច្ចយ៉ាងខ្លាំង ។ គិតជាសរុប ប្រាក់កំរៃនៅតាមព្រំដែន

*តទៅទំព័រទី ១៩*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

## កំណើនសេដ្ឋកិច្ចពិភពលោក

នៅត្រីមាសទី៣ ២០០៦ ផសស ពិត នៅ US កើនឡើងតាមអត្រាប្រចាំឆ្នាំ ២,២% ធៀបនឹងកំណើន ២,៦% នៅត្រីមាសទី២ ។ រឿងនេះ បង្ហាញជាសំខាន់ពីកំណើនការនាំចូល និងការធ្លាក់ចុះនៃវិនិយោគលើការសាងសង់ផ្ទះ វិនិយោគលើសារពើភ័ណ្ឌ ចំណាយប្រើប្រាស់លើសេវាកម្ម និងចំណាយរបស់រដ្ឋាភិបាលសហព័ន្ធ ។

នៅត្រីមាសទី៣ ផសស ពិត នៅតំបន់អឺរ៉ូ កើនឡើង ២,៦% ធៀបនឹងពេលដូចគ្នាឆ្នាំមុន និងកើន ០,៥% ធៀបនឹងត្រីមាសមុន ។ ផសស ពិត នៅជប៉ុន កើន ២,៧% ធៀបនឹងឆ្នាំមុន និង ០,៧% ធៀបនឹងត្រីមាសមុន ។

កំណើនសេដ្ឋកិច្ចនៅចិន ធ្លាក់ចុះមកត្រឹម ១០,៤% នៅត្រីមាសទី៣ ធៀបនឹងកំណើន ១១,៣% នៅត្រីមាសមុន ។ វិស័យឧស្សាហកម្ម បន្តកើនឡើងក្នុងល្បឿនលឿនជាងវិស័យសេវាកម្ម និងវិស័យកសិកម្ម ហើយការវិនិយោគ និងការនាំចេញ នៅតែជាកត្តាជំរុញសំខាន់នៃកំណើននេះ ។ ផសស ពិត នៅកូរ៉េខាងត្បូង នៅត្រីមាសទី៣ កើន ៤,៨% ធៀបនឹងឆ្នាំមុន និង ១,១% ធៀបនឹងត្រីមាសមុន ។ នៅត្រីមាសទី៣ ផសស ពិត នៅតៃវ៉ាន់ និងហុងកុង កើន ៥,០% និង ៦,៨% ធៀបនឹងអំឡុងពេលដូចគ្នាឆ្នាំមុន ។

នៅត្រីមាសទី៣ សេដ្ឋកិច្ចម៉ាឡេស៊ី កើន ៥,៨% ធៀបនឹងពេលដូចគ្នាឆ្នាំមុន ។ អនុវិស័យផលិត និងវិស័យសេវាកម្ម កើន ៧,១% និង ៦,៥% រីឯវិស័យកសិកម្ម កើន ៦,២% ។ នៅផ្នែកចំណាយ ការចំណាយលើទំនិញប្រើប្រាស់ចុងក្រោយ និងនាំចេញ កើន ៧,១% និង ១០,៥% ធៀបនឹងឆ្នាំមុន ។

នៅត្រីមាសទី៣ សេដ្ឋកិច្ចសិង្ហបុរី កើន ៧,១% ធៀបនឹងពេលដូចគ្នាឆ្នាំ២០០៥ ។ ផ្នែកផលិត កើនឡើង ១០,០% រីឯវិស័យសេវាកម្ម កើនឡើង ៦,៦% ។ កំណើនសមល្មមនៃផ្នែកផលិត បណ្ដាលមកពីការធ្លាក់ចុះកំណើនក្នុងការផលិតជីវឱសថ គ្រឿងអេឡិចត្រូនិក និងវត្ថុគីមី ។

នៅត្រីមាសទី៣ ផសស ពិត នៅថៃ កើន ៤,៧% ធៀបនឹងពេលដូចគ្នាឆ្នាំ២០០៥ ។ វិស័យកសិកម្ម កើន ៥,២% គឺតិចជាងកំណើននៅត្រីមាសមុន ដោយសារការធ្លាក់ចុះផលដំណាំ និងការចិញ្ចឹមសត្វ ។ វិស័យមិនមែនកសិកម្ម កើន ៤,៧% ធៀបនឹងឆ្នាំមុន ប៉ុន្តែទាបជាងកំណើន ៤,៩% នៅត្រីមាសមុន ។ ការធ្លាក់ចុះកំណើនក្នុងវិស័យមិនមែនកសិកម្ម បណ្ដាលមកពីការធ្លាក់ចុះនៃឧស្សាហកម្មវត្ថុធាតុដើម ទំនិញមូលធន និងទំនិញបច្ចេកវិទ្យាខ្ពស់ ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់នៅទីផ្សារអន្តរជាតិ

នៅត្រីមាសទី៣ ២០០៦ ភាពធូរស្រាលក្នុងទីផ្សារប្រេងឆៅពិភពលោក គឺជាកត្តារួមគ្នា ដែលជួយទប់ស្កាត់អតិផរណានៅប្រទេសសេដ្ឋកិច្ចធំៗបំផុតក្នុងពិភពលោក ។ ថ្លៃទំនិញប្រើប្រាស់នៅរយៈ១២ខែ កើន ៣,៣% នៅ US ០,៦% នៅជប៉ុន និង ២,១% នៅតំបន់អឺរ៉ូ ដោយធ្លាក់ចុះពី ៤,០% ០,៧% និង ២,៣% នៅត្រីមាសមុន ។ នៅបណ្ដាប្រទេសអាស៊ាន អតិផរណាមានកំរិតថេរជាទូទៅ ។ នៅត្រីមាសទី៣ ម៉ាឡេស៊ី សិង្ហបុរី និងថៃ មានអតិផរណា ៣,៦% ០,៧% និង ៣,៦% ធៀបនឹង ៤,១% ១,២% និង ៦,០% នៅត្រីមាសមុន ។

ដុល្លារUS ឡើងថ្លៃទល់នឹងប្រាក់យ៉េនជប៉ុន ប៉ុន្តែបន្តធ្លាក់ថ្លៃទល់នឹងរូបិយវត្ថុចំបងៗ ។ ១ដុល្លារUS ប្តូរបាន ១១៦,៣យ៉េន រឺឡើងថ្លៃ ៤,៦% ធៀបនឹងត្រីមាសមុន ។ នៅអំឡុងពេលដូចគ្នា វាប្តូរបាន ០,៧៨អឺរ៉ូ/ដុល្លារUS ដោយធ្លាក់ចុះពី ០,៨០អឺរ៉ូ/ដុល្លារUS នៅត្រីមាសមុន ។ ដុល្លារUS ក៏ធ្លាក់ថ្លៃដែរ ទល់នឹងប្រាក់វ៉ុនកូរ៉េ ប្រាក់យ៉ុនចិន និងដុល្លារសិង្ហបុរី ។

## ថ្លៃផលិតផលនៅលើទីផ្សារពិភពលោក

នៅត្រីមាសទី៣ ថ្លៃអង្ករ ពោត ប្រេងឆា សណ្ដែកសៀង និង ប្រេងឆៅ កើនឡើង រីឯថ្លៃសាំង និងម៉ាស៊ូត ធ្លាក់ចុះ ។ អង្ករថៃ 100% B លេខ២ នៅទីផ្សារបាងកក លក់ថ្លៃ ២៨៩,៩១ដុល្លារ/តោន ដោយឡើងថ្លៃពី ២៨៣,៨៦ដុល្លារ/តោន នៅត្រីមាសទី២ ។ ប្រេងឆា លក់ថ្លៃ ៤៤៦,៨៥ដុល្លារ/តោន ដោយឡើងថ្លៃពី ៣៩៧,៨៧ដុល្លារ/តោន រីឯពោត និងសណ្ដែកសៀង លក់ថ្លៃ ១០៨,៦៧ដុល្លារ/តោន និង ២០៧,៣៨ដុល្លារ/តោន ។ នៅត្រីមាសទី៣ ថ្លៃប្រេងឆៅ កើន ៣,០% ធៀបនឹងត្រីមាសមុន ដល់ ៦៧,០០ដុល្លារ/ធុង ។ ថ្លៃសាំង និងម៉ាស៊ូត ធ្លាក់ចុះ ៥,៧% និង ០,៤% ធៀបនឹងត្រីមាសមុន ។ សាំង លក់ថ្លៃ ៥២,៧០សេន/លីត្រ និង ម៉ាស៊ូត លក់ថ្លៃ ៥៥,៦៦សេន/លីត្រ ។

*រៀបរៀងដោយ ហ៊ីង វុត្ថា និង ភឹម រុនស៊ីណារិទ្ធិ*

**តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៦ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)**

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | | 2005 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 6.7 | 4.8 | 7 | 7.7 | - | - | - | - | - | 13.4 |
| ឥណ្ឌូនេស៊ី | 3.8 | 3.8 | 4.9 | 5.1 | 5.3 | 4.9 | 4.6 | 5.2 | 5.5 | 5.6 |
| ម៉ាឡេស៊ី | 0.5 | 5.6 | 5.4 | 7 | 5.3 | 5.2 | 5.5 | 5.9 | 5.8 | 5.2 |
| សិង្ហបុរី | -2.3 | 2.6 | 1.4 | 8.5 | 7 | 7.7 | 10.7 | 8.0 | 7.1 | 5.7 |
| ថៃ | 1.9 | 6.1 | 6.9 | 6 | 5.3 | 4.7 | 6.0 | 4.9 | 4.7 | 4.5 |
| វៀតណាម | 6.0 | 6.7 | 7 | 7.5 | - | - | - | - | - | 8.4 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 7.5 | 8.1 | 9.9 | 9.5 | 9.4 | 9.9 | 10.9 | 11.3 | 10.4 | 9.6 |
| ហុងកុង | 0.5 | 5.0 | 3.2 | 8.3 | 8.2 | 7.6 | 8.2 | 5.2 | 6.8 | 6.5 |
| កូរ៉េខាងត្បូង | 3.0 | 6.1 | 3 | 4.7 | 4.4 | 5.2 | 6.1 | 5.3 | 4.8 | 4.7 |
| តៃវ៉ាន់ | -2.2 | 4.2 | 3.1 | 5.7 | - | 6.0 | 4.9 | 4.6 | 5.0 | - |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 1.4 | 0.7 | 0.5 | 1.8 | 1.5 | 1.8 | 2.0 | 2.4 | 2.6 | 1.5 |
| ជប៉ុន | 0.4 | 0.4 | 2.6 | 3.4 | 2.9 | 4.5 | 3.0 | 2.2 | 2.7 | 2.5 |
| សហរដ្ឋអាមេរិក | 1.2 | 2.4 | 3.1 | 4.4 | 4.1 | 1.1 | 5.6 | 2.6 | 2.2 | 3.0 |

*Sources: Economist, countries' national statistics offices and central banks and ADB's Asia Regional Information Centre*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

### តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៦ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2001 | 2002 | 2003 | 2004 | 2005 | | 2006 | | | 2005 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | -0.6 | 3.2 | 1.2 | 4.0 | 4.6 | 6.6 | 6.1 | 4.5 | 4.9 | 5.8 |
| ឥណ្ឌូនេស៊ី | 11.5 | 13.2 | 8.3 | 8.3 | 12 | 17.3 | 25.1 | 23.4 | 22.9 | 10.5 |
| ម៉ាឡេស៊ី | 1.4 | 1.8 | 1.1 | 1.6 | 3.4 | 3.4 | 3.9 | 4.1 | 3.6 | 3.1 |
| សិង្ហបុរី | 1.0 | -0.4 | 0.5 | 1.7 | 0.5 | 1.1 | 1.4 | 1.2 | 0.7 | 0.5 |
| ថៃ | 1.7 | 0.6 | 1.8 | 2.7 | 5.6 | 6.0 | 5.7 | 6.0 | 3.6 | 4.5 |
| វៀតណាម | -0.4 | 3.8 | 3.2 | 8.3 | 7.5 | 10.0 | 10.3 | - | - | 8.2 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 0.9 | -0.7 | 1.2 | 3.9 | 1.3 | 1.4 | 1.2 | 1.4 | 1.4 | 1.8 |
| ហុងកុង | -1.3 | -3.0 | -2.6 | -0.4 | 1.4 | 1.8 | 2.0 | 2.1 | 2.3 | 1.1 |
| កូរ៉េខាងត្បូង | 4.4 | 2.7 | 3.5 | 3.5 | 2.4 | 2.5 | 2.4 | 2.3 | 2.5 | 2.8 |
| តៃវ៉ាន់ | -0.01 | -0.2 | -0.3 | 1.6 | 3.0 | 2.5 | 1.4 | 1.5 | -0.3 | 2.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 2.6 | 2.2 | 2.1 | 2.2 | 2.3 | 2.4 | 2.3 | 2.3 | 2.1 | 2.2 |
| ជប៉ុន | -0.6 | -0.9 | -0.3 | Nil | -0.3 | -0.5 | 0.4 | 0.7 | 0.6 | -0.3 |
| សហរដ្ឋអាមេរិក | 2.8 | 1.6 | 2.3 | 2.7 | 3.8 | 3.7 | 3.7 | 4.0 | 3.3 | 3.4 |

*Sources: International Monetary Fund, Economist and National Institute of Statistics*

### តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៦ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2001 | 2002 | 2003 | 2004 | 2005 | | 2006 | | | 2005 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា (រៀល) | 3,916.3 | 3,912.1 | 3,973 | 4,016.3 | 4,134.3 | 4,154.3 | 4,081.3 | 4,095.3 | 4145.3 | 4,092.5 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 10,261 | 9,311 | 8,577 | 8,938 | 9,994 | 9,999 | 9,175 | 9,115 | - | 9,705 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.80 | 3.80 | 3.80 | 3.80 | 3.77 | 3.78 | 3.73 | 3.65 | 3.67 | 3.79 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.79 | 1.79 | 1.74 | 1.69 | 1.68 | 1.69 | 1.63 | 1.59 | 1.58 | 1.66 |
| ថៃ (បាត) | 44.4 | 42.9 | 41.5 | 40.2 | 41.3 | 41.02 | 39.3 | 38.1 | 37.7 | 40.2 |
| វៀតណាម (ដុង) | 14,725 | 15,280 | 15,510 | - | 15,878 | 15,907 | 15,921 | - | - | 15,859 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន (យ៉ាន់) | 8.28 | 8.28 | 8.28 | 8.28 | 8.14 | 8.08 | 8.05 | 8.01 | 7.97 | 8.19 |
| ហុងកុង (ដុល្លារហុងកុង) | 7.80 | 7.80 | 7.78 | 7.79 | 7.77 | 7.75 | 7.76 | 7.76 | 7.78 | 7.78 |
| កូរ៉េខាងត្បូង (វ៉ុន) | 1,291 | 1,251 | 1,192 | 1,145 | 1,029 | 1,036 | 976 | 949 | 955 | 1,024 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 33.8 | 34.5 | 34.4 | 33.6 | 32.3 | 33.4 | 32.3 | 32.2 | 32.8 | 32.1 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 1.12 | 1.06 | 0.89 | 0.80 | 0.81 | 0.84 | 0.83 | 0.80 | 0.78 | 0.80 |
| ជប៉ុន (យ៉េន) | 121.5 | 125.4 | 115.9 | 108.2 | 111.2 | 117.2 | 116.9 | 114.5 | 116.3 | 110.2 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

### តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០១-២០០៦ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2001 | 2002 | 2003 | 2004 | 2005 | | 2006 | | | 2005 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | |
| ពោត (US No. 2) - US ($/តោន) | 81.18 | 89.98 | 95.42 | 110.65 | 90.61 | 90.64 | 95.37 | 99.95 | 108.67 | 89.19 |
| ប្រេងឆា- អឺរ៉ុបពាយព្យ ($/តោន) | 259.13 | 353.91 | 402.03 | 427.47 | 376.41 | 391.52 | 395.75 | 397.87 | 446.85 | 381.32 |
| អង្ករ (Thai 100%B) – បាងកក ($/តោន) | 160.81 | 178.59 | 182.22 | 221.67 | 255.77 | 259.40 | 275.12 | 283.86 | 289.91 | 262.88 |
| សណ្តែកសៀង (US No. 1) – US ($/តោន) | 163.89 | 182.58 | 218.86 | 262.03 | 214.37 | 210.42 | 210.96 | 207.02 | 207.38 | 224.25 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 22.8 | 23.9 | 26.8 | 33.5 | 57.27 | 52.99 | 57.89 | 65.03 | 67.00 | 50.14 |
| សាំង – US Gulf coast (សេន/លីត្រ) | 19.5 | 19.1 | 23 | 30.9 | 52.37 | 42.29 | 41.18 | 55.89 | 52.70 | 42.19 |
| ម៉ាស៊ូត (ស្តង់ដារតិច លេខ២) – US Gulf coast (សេន/លីត្រ) | 18.72 | 17.85 | 21.63 | 29.48 | 50.02 | 49.90 | 47.72 | 55.89 | 55.66 | 44.35 |

*Sources: Food and Agriculture Organisation and US Energy Information Administration.*
*Note: All prices have been converted from US$/ton to US$/tonne. 1 ton = 0.907 tonne.*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី៣ ឆ្នាំ២០០៦ គំរោងវិនិយោគឯកជនបានអនុម័ត ធ្លាក់ចុះយ៉ាងខ្លាំង នៅខណៈដែលវិស័យទេសចរណ៍ គំរោងសាងសង់បានអនុម័ត និងជញ្ជីងពាណិជ្ជកម្ម កើនឡើង ។

នៅត្រីមាសទី៣ ឆ្នាំ២០០៦ គំរោងវិនិយោគឯកជនបានអនុម័តនៅកម្ពុជា រួមទាំងគំរោងពង្រីកបន្ថែមផង បានធ្លាក់ចុះយ៉ាងខ្លាំងអស់ ៣៤% ធៀបនឹងត្រីមាសដូចគ្នា២០០៥ និងអស់ ៨៩% ធៀបនឹងត្រីមាសមុន មកត្រឹម ២៦៦,២លានដុល្លារ ។ ការធ្លាក់ចុះនេះ បណ្តាលជាសំខាន់មកពីការធ្លាក់ចុះគំរោងអនុម័តក្នុងវិស័យកសិកម្ម និងវិស័យសេវាកម្ម គិតជាទ្រព្យសកម្មជាប់លាប់ ។ គំរោងអនុម័តក្នុងវិស័យកសិកម្ម ធ្លាក់ចុះពី ២១៦,៩លានដុល្លារ នៅត្រីមាសមុន មកត្រឹមកំរិតសូន្យ នៅត្រីមាសទី៣ ។ គំរោងអនុម័តក្នុងវិស័យសេវាកម្ម ធ្លាក់ចុះអស់ ៩៥% មកត្រឹម ៩៤,៥លានដុល្លារ ធៀបនឹងត្រីមាសមុន ។ ការធ្លាក់ចុះនេះ បណ្តាលមកពីការថយចុះវិស័យសាងសង់អស់ ១០០% និងគំរោងអនុម័តក្នុងវិស័យសណ្ឋាគារនិងទេសចរណ៍ អស់ ៨៧% (មកត្រឹម ៣,៥លានដុល្លារ) ។ នៅខណៈនេះដែរ គំរោងវិនិយោគបានអនុម័តក្នុងវិស័យឧស្សាហកម្ម កើនមួយជាពីរ ដល់ ១៧១,៧លានដុល្លារ ។ កត្តាជំរុញនៃកំណើនគំរោងវិនិយោគអនុម័តក្នុងវិស័យឧស្សាហកម្ម គឺកំណើនមួយជាពីរនៃវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ក្នុងវិស័យកាត់ដេរ ដល់ ២៣,២លានដុល្លារ និងការវិនិយោគដ៏ធំក្នុងផលិតកម្មស៊ីម៉ង់ត៍ចំនួន ១៣២,០លានដុល្លារ ។ ទោះជាយ៉ាងនេះក្តី ដោយសារការអនុមតិក្នុងត្រីមាសទី៣នេះ នឹងមានគំរោងក្នុងវិស័យឧស្សាហកម្មចំនួន ១៤គំរោង ដែលអាចស្រូបយកកំលាំងពលកម្ម ២២.៥៨៨នាក់ និងគំរោងក្នុងវិស័យសេវាកម្ម ៦គំរោង ដែលត្រូវការកំលាំងពលកម្ម ១.០៥៩នាក់ ។

ការអនុមតិគំរោងសាងសង់នៅភ្នំពេញ បន្តកើនឡើងនៅត្រីមាសទី៣ ឆ្នាំ២០០៦ ។ ការអនុមតិសរុប មានតំលៃ ៩៥,៥លានដុល្លារ រឺកើន ២៥% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន និង ១៦% ធៀបនឹងត្រីមាសមុន ។ កំនើននេះ បណ្តាលមកពីកំណើននៃការអនុមតិសំណង់ភូមិគ្រឹះ និងផ្ទះ (៣៣%) និងសំណង់ផ្ទះល្វែង (៣០%) ។ ធៀបនឹងត្រីមាសដូចគ្នា ២០០៥ សំណង់ផ្ទះល្វែង និងសំណង់ផ្សេងៗទៀត កើន ៦២% និង ៣០% រីឯសំណង់ភូមិគ្រឹះ និងផ្ទះ ធ្លាក់ចុះ ៦០% ។

នៅត្រីមាសទី៣ ឆ្នាំ២០០៦ ជញ្ជីងពាណិជ្ជកម្ម មានអតិរេក ២៣,២លានដុល្លារ ធៀបនឹងឱនភាព ១២២,៤លានដុល្លារ នៅត្រីមាសមុន ។ អតិរេកមានកំរិត ៧៦% តិចជាងត្រីមាសដូចគ្នាឆ្នាំមុន ប៉ុន្តែការនាំចេញរបស់កម្ពុជា កើនឡើង ។ ទោះបីជាការនាំចូលសរុបកើនឡើងក្តី វាមានកំរិតតែ ៩៧% នៃការនាំចេញសរុបប៉ុណ្ណោះ គឺបានន័យថា ការនាំចេញមានគ្រប់គ្រាន់សំរាប់ទូទាត់ការនាំចូលក្នុងត្រីមាសនេះ ។ ការនាំចេញសរុបមានចំនួន ៨០៧,៥លានដុល្លារ រឺកើន ១០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន និង ២៤% ធៀបនឹងត្រីមាសមុន ។ ការនាំចេញខាងវិស័យកាត់ដេរ កើន ២៤% ដល់ ៧៨២,០លានដុល្លារ ក្នុងនេះមាន ៦៧% បាននាំចេញទៅ US (កើន ១៩%) និង ២៤% ទៅតំបន់អឺរ៉ូ (កើន ៣២%) ។ ការនាំចេញសំលៀកបំពាក់ មាន ៧៥៨,៥លានដុល្លារ រឺកើន ២៧% ធៀបនឹងត្រីមាសមុន ។ ការនាំចេញស្បែកជើង និងផលិតផលវាយនភ័ណ្ឌផ្សេងទៀត មាន ១៨,៩លានដុល្លារ (កើន ៥៩%) និង ៤,៥លានដុល្លារ (កើន ៥០%) ។ កិច្ចព្រមព្រៀងពាណិជ្ជកម្ម ដែលកំណត់ការនាំចូលផលិតផលវាយនភ័ណ្ឌចិនទៅ US បានផ្តល់នូវការគាំពារបណ្តោះអាសន្នដល់ការនាំចេញផលិតផលកាត់ដេរកម្ពុជា ដែលបន្តមានកំណើនរហូតដល់កិច្ចព្រមព្រៀងនេះបញ្ចប់នៅខែធ្នូ ឆ្នាំ២០០៨ ។ ដូច្នេះ កំណើននៃការនាំចេញខាងវិស័យកាត់ដេរ បង្ហាញពីអនាគតល្អក្នុងរយៈពេលខ្លី របស់វិស័យឧស្សាហកម្មកាត់ដេរកម្ពុជា ប៉ុន្តែអនាគតក្នុងនៅរយៈពេលវែង នៅតែមិនទាន់ច្បាស់លាស់ ។ ការនាំចេញខាងវិស័យកសិកម្ម កើនឡើង ២៦% ដល់ ២៥,៥លានដុល្លារ នៅត្រីមាសទី៣ ឆ្នាំ២០០៦ ។ ធៀបនឹងត្រីមាសមុន ការនាំចេញកៅស៊ូ កើន ៣៩% និងការនាំចេញត្រី កើន ៣៨% រីឯការនាំចេញឈើ និងការនាំចេញផ្សេងទៀត កើន ៨,៧% និង ១០% ។

នៅត្រីមាសទី៣ ឆ្នាំ២០០៦ ការនាំចូលរបស់កម្ពុជា បន្តកើនឡើង ប៉ុន្តែក្នុងកំរិតតិចត្រឹម ១,២% ធៀបនឹងត្រីមាសមុន ដល់ ៧៨៤,៣លានដុល្លារ ។ ធៀបនឹងត្រីមាសដូចគ្នា ២០០៥ ការនាំចូលសរុប កើន ២៤% ។ សាំង និងសំភារៈសំណង់ កើន ៥,៦% ដល់ ១៣,១លានដុល្លារ និង ៨,៧% ដល់ ៤២,៥លានដុល្លារ រីឯការនាំចូលម៉ាស៊ូត ធ្លាក់ចុះ ៦,៥% មកត្រឹម ៣០,១លានដុល្លារ ។ ទំហំការនាំចូលសាំងសរុប មាន ៤១.៩០០តោន រឺកើន ៥,៣% រីឯការនាំចូលម៉ាស៊ូត មាន ១២០.៧០០តោន រឺកើន ៤,៨% ។

នៅត្រីមាសទី៣ ឆ្នាំ២០០៦ ភ្ញៀវបរទេសមកដល់សរុប កើនបន្តិចត្រឹម ៣,៥% ដល់ ៣៧០.៦២០នាក់ ។ ចំនួននេះ រំពឹងថានឹងកើនថែមទៀតនៅខែក្រោយៗ ដោយសារការរៀបចំតាំងពិព័រណ៍វប្បធម៌កូរ៉េ-កម្ពុជា ក្នុងខេត្តសៀមរាប នៅរវាងខែវិច្ឆិកា ២០០៦ និងខែមករា ២០០៧ ។ ភ្ញៀវបរទេស មកសំរាកលំហែ មានចំនួន ៣២២.៣៨០នាក់ រឺកើន ១០% ធៀបនឹងត្រីមាសមុន និងស្មើ ៨៧% នៃចំនួនភ្ញៀវបរទេសសរុបមកដល់កម្ពុជា ។ ក្នុងចំណោមនេះ ភ្ញៀវមកតាមផ្លូវអាកាស កើន ៩,៧% ដល់ ២២៤.២០២នាក់ ដោយអាកាសយានដ្ឋានភ្នំពេញ ទទួលបាន ១០១.៥៧៥នាក់ និងសៀមរាប ទទួលបាន ១២២.៦២៧នាក់ ។ ភ្ញៀវមកតាមផ្លូវគោកនិង ផ្លូវទឹក កើន ៤,៧% ដល់ ១៤៦.៤១៨នាក់ ដែលក្នុងនេះ ភ្ញៀវតាមផ្លូវគោក មាន ១៣៧.៤១១នាក់ និងតាមផ្លូវទឹក មាន ៩.០០៧នាក់ ។ នៅត្រីមាស ទី៣ ភ្ញៀវបរទេសសរុបមកដល់ខេត្តសៀមរាប មាន ១៨៦.៧៤០នាក់ និងមកដល់ភ្នំពេញនិងទីកន្លែងផ្សេងទៀត មាន ១៨៣.៨៨០នាក់ ។ ភ្ញៀវកូរ៉េ មានច្រើនជាងគេ ដល់ ៥៣.៦៨៦នាក់ រឺ ១៤,៥% នៃភ្ញៀវបរទេសសរុប ហើយបន្ទាប់មកគឺជប៉ុន ដែលមាន ៤០.០៧៩នាក់ រឺ ១១% ។

## ហិរញ្ញវត្ថុសាធារណៈ

ឱនភាពថវិការបស់រដ្ឋាភិបាល មាន ១៩១,៩ពាន់លានរៀល នៅត្រីមាសទី៣ ឆ្នាំ២០០៦ ។ ឱនភាពនេះ ធ្លាក់ចុះ ៣២% ធៀបនឹងត្រីមាសទី២ ។ ការប្រមូលចំណូលថវិកា កើនឡើង រីឯចំណាយថវិកាធ្លាក់ចុះ ។ ចំណូលមូលធនកើនមួយជាបួន ធៀបនឹងត្រីមាសមុន ដល់ ១៥,៤ពាន់លានរៀល ដោយសារចំណូលពីឯកជនភាវូបនីយកម្ម រីឯចំណូលចរន្ត មាន ៧១៦,៨ពាន់លានរៀល រឺធ្លាក់ចុះ ១,៤% ។ ចំណូលមិនមែនពន្ធ ធ្លាក់ចុះ ១០% ធៀបនឹងត្រីមាសមុន មកត្រឹម ១៥១,០ពាន់លានរៀល ។ កត្តាជំរុញឱ្យមានការធ្លាក់ចុះចំណូល

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

មិនមែនពន្ធ គឺការធ្លាក់ចុះយ៉ាងខ្លាំងនៃចំណូលពីការធ្វើអាជីវកម្មព្រៃឈើ អស់ ៥៧% មកត្រឹម ០,៣ពាន់លានរៀល និងចំណូលខាងប្រៃសណីយ៍និងទូរគមនាគមន៍ អស់ ៦១% មកត្រឹម ១១,៧ពាន់លានរៀល ហើយនិងការធ្លាក់ចុះតិចតួចនៃចំណូលកូតានិងអាជ្ញាប័ណ្ណនាំចេញអស់ ២,៦% មកត្រឹម ៣០,២ពាន់លានរៀល និងចំណូលខាងទេសចរណ៍អស់ ៨,៨% មកត្រឹម ១២,៤ពាន់លានរៀល ។ នៅខណៈនេះដែរ ចំណូលពន្ធ កើន ១,៣% ដល់ ៥៦៥,៨ពាន់លានរៀល រឺ ៧៧% នៃការប្រមូលចំណូលសរុប ។ ការប្រមូលចំណូលពីអាករលើតំលៃបន្ថែម (VAT) ពន្ធគយ និងអាករពិសេស កើនឡើងបន្តិចត្រឹម ៩,៦% (២១៦,៣ពាន់លានរៀល) ៣,៦% (១៥៧,២ពាន់លានរៀល) និង ០,៣% (១០៣,៣ពាន់លានរៀល) ។

នៅត្រីមាសទី៣ ឆ្នាំ២០០៦ ចំណាយថវិកា ធ្លាក់ចុះ ៨,៧% ធៀបនឹងត្រីមាសទី២ មកត្រឹម ៩២៤,០ពាន់លានរៀល ។ ចំណាយចរន្តដែលមានចំនួន ៦០៦,៩ពាន់លានរៀល រឺ ៦៦% នៃចំណាយសរុប ធ្លាក់ចុះ ៣,០% ហើយចំណាយមូលធន ធ្លាក់ចុះ ១៨% មកត្រឹម ៣១៧,២ពាន់លានរៀល ។ ចំណាយលើការអប់រំនិងសុខាភិបាល ធ្លាក់ចុះ ២៦% មកត្រឹម ១៥៥,៣ពាន់លានរៀល និងចំណាយលើសេវាកម្មសង្គមនិងរដ្ឋបាលផ្សេងៗ ចុះអស់ ១,៦% មកត្រឹម ៣០១,៥ពាន់លានរៀល រីឯចំណាយលើសន្តិសុខនិងការពារជាតិ កើន ៣៣% ដល់ ១៥៥,៣ពាន់លានរៀល ។ ចំណាយមូលធន ក៏ធ្លាក់ចុះ ១៨% ធៀបនឹងត្រីមាសមុន មកត្រឹម ៣០៧,២ពាន់លានរៀល ។ មូលនិធិសំរាប់ចំណាយមូលធន មាន ៧៤% បានមកពីជំនួយខាងក្រៅ និង ២៦% បានមកពីហិរញ្ញប្បទានក្នុងស្រុក ។

## អតិផរណា និងអត្រាប្ដូរប្រាក់

នៅត្រីមាសទី៣ ឆ្នាំ២០០៦ ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញ កើន ៣,១% ធៀបនឹងត្រីមាសទី២ ។ ថ្លៃអាហារ និងថ្លៃដឹកជញ្ជូននិងទូរគមនាគមន៍ កើន ៤,៦% និង ២,៥% ធៀបនឹងត្រីមាសមុន ។ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០០៥ ថ្លៃទំនិញទូទៅ កើន ៤,៩% រីឯថ្លៃអាហារ និងថ្លៃដឹកជញ្ជូននិងទូរគមនាគមន៍ កើន ៥,៨% និង ១០% ។ ទោះជាយ៉ាងនេះក្ដី កំណើនប្រចាំឆ្នាំនៃថ្លៃអាហារ និងថ្លៃដឹកជញ្ជូននិងទូរគមនាគមន៍ ក្នុងរយៈមួយឆ្នាំដល់ត្រីមាសទី៣ ២០០៦ វាតិចជាងកំណើនក្នុងរយៈ១២ខែ ដល់ត្រីមាសទី៣ ២០០៥ ។

នៅត្រីមាសទី៣ ប្រាក់រៀល ប្ដូរបាន ៤.១៤៥,៣រៀល/ដុល្លារUS រឺធ្លាក់ថ្លៃ ០,៩% ធៀបនឹងត្រីមាសទី២ និង ០,៣% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ មុន ។ ប្រាក់រៀល ក៏ធ្លាក់ថ្លៃ ២,១% ទល់នឹងប្រាក់បាតថៃ មកត្រឹម ១១០,៣រៀល/បាត ។ ទោះជាយ៉ាងនេះក្ដី នៅត្រីមាសទី៣ ឆ្នាំ ២០០៦ ប្រាក់រៀល ឡើងថ្លៃបន្តិចបាន ០,៤% ទល់នឹងប្រាក់ដុងវៀតណាម ដោយប្ដូរបាន ២៤,៩រៀល/១០០ដុង ។ ការធ្លាក់ថ្លៃប្រាក់រៀលនេះ ផ្ដល់ផលចំណេញដល់ប្រជាជនជាច្រើននៅក្នុងទីក្រុងដែលមានកាន់រូបិយវត្ថុបរទេស (ឧ. ប្រាក់ដុល្លារUS) រីឯប្រជាជនរស់នៅជនបទ ដែលនិយមកាន់រូបិយវត្ថុក្នុងស្រុក គឺមិនសូវបានផលចំណេញទេ ។

## ការវិវត្តន៍រូបិយវត្ថុ

យោងតាមអង្កេតលើរូបិយវត្ថុកម្ពុជា រូបិយវត្ថុទូទៅ (M2) នៅត្រីមាសទី៣ ២០០៦ កើន ៦,៩% ដល់ ៦.៤៦១,០ពាន់លានរៀល ។ រូបិយវត្ថុក្នុងចរាចរ កើន ៣,៦% ដល់ ១.៥១២,៤ពាន់លានរៀល ។ បញ្ញើជាប្រាក់រៀល ធ្លាក់ចុះ ១៣% ធៀបនឹងត្រីមាសមុន មកត្រឹម ១៤៤,០ពាន់លានរៀល រីឯបញ្ញើជារូបិយវត្ថុបរទេស កើន ៨,៧% ។ ទ្រព្យសកម្មក្នុងស្រុកសុទ្ធ (Net Domestic Assets: NDA) កើន ១១% ដល់ ៤៩៧,២ពាន់លានរៀល ក្នុងនេះឥណទានក្នុងស្រុក កើន ១១% ដល់ ២.៣៩៨,៦ពាន់លានរៀល ហើយប្រាក់បញ្ញើ និងធនបំរុងដទៃទៀត កើន ៣,៣% ដល់ ២.៨៩៥,៨ពាន់លានរៀល ។ ក្នុងចំណោមសមាសភាគនៃឥណទានក្នុងស្រុក ឥណទានក្នុងវិស័យឯកជន កើន ៩,៨% ដល់ ៣.២៩០,២ពាន់លានរៀល រីឯឥណទានរដ្ឋាភិបាលសុទ្ធ ធ្លាក់ចុះ ៧,៣% ដល់ ៨៩១,៦ពាន់លានរៀល ។ ប្រាក់បញ្ញើរបស់រដ្ឋាភិបាល កើន ៥,២% ដល់ ១.១៦២,១ពាន់លានរៀល នៅត្រីមាសទី៣ ។ ទ្រព្យសកម្មបរទេសសុទ្ធ (Net Foreign Assets: NFA) កើន ៤,១% ធៀបនឹងត្រីមាសមុន ដល់ ៦.៩៥៨,៣ពាន់លានរៀល ។ កំណើននៃទ្រព្យ សកម្មបរទេសសុទ្ធ និងទ្រព្យសកម្មក្នុងស្រុកសុទ្ធ ធ្វើអោយការផ្គត់ផ្គង់រូបិយវត្ថុ និងរូបិយវត្ថុក្នុងចរាចរ រីកធំឡើង ។ កំណើនទាំងនេះ ជាធម្មតា ត្រូវកាត់កងមកវិញដោយកំណើននៃប្រាក់បញ្ញើរបស់រដ្ឋាភិបាល ដែលយក រូបិយវត្ថុចេញពីចរាចរ ហើយនេះជាការឆ្លើយតបដោយចេតនាខាងគោលនយោបាយដើម្បីធានាស្ថិរភាពថ្លៃ ។

## ស្ថានភាពក្រីក្រ និងប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះ

យោងតាមអង្កេតរបស់ CDRI-វិបសអ លើពលករងាយរងគ្រោះនៅខែវិច្ឆិកា ឆ្នាំ២០០៦ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នកលីសែង អ្នករត់តុ អ្នកស៊ីឈ្នួលធ្វើស្រែ និងកម្មករកាត់ដេរ កើនឡើង រីឯប្រាក់ចំណូលរបស់អ្នកធាក់ស៊ីក្លូ អ្នកលក់បន្លែតូចតាច អ្នករើសអេតចាយ អ្នករត់ម៉ូតូឌុប កម្មករសំណង់មានជំនាញ និងគ្មានជំនាញ បានធ្លាក់ចុះធៀបនឹងអំឡុងពេល ដូចគ្នា ឆ្នាំ២០០៥ ។

ដូចបានបង្ហាញក្នុងតារាង៨ នៅខែវិច្ឆិកា ឆ្នាំ២០០៦ ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នករត់ម៉ូតូឌុប ធ្លាក់ចុះ ១៣% ធៀបនឹងអំឡុងពេលដូចគ្នាឆ្នាំ២០០៥ មកត្រឹម ៨៣៨៦រៀល ។ កំណើននៃចំនួនយានទុកទុក និងម៉ូតូឌុប គឺជាមូលហេតុចំបងដែលនាំអោយប្រាក់ចំណូលធ្លាក់ចុះ ។ អ្នករត់ម៉ូតូឌុប ប្រហែល ៩០% ជាអ្នកមកពីខេត្ត ដូចជា ព្រៃវែង ស្វាយរៀង តាកែវ កំពង់ចាម និងកណ្ដាល ។ ក្នុងចំនួននេះ ៧០% មកភ្នំពេញតែម្នាក់ឯង រីឯ ៣០% ទៀត មកជាមួយក្រុមគ្រួសារ ។ អ្នករត់ម៉ូតូឌុបភាគច្រើន ទទួលទានអាហារនៅតាមតូបលក់បាយនៅជុំវិញ/ក្នុងផ្សារ ហើយចំណាយពី ២៥០០រៀល ទៅ ៥០០០រៀល ក្នុងមួយថ្ងៃ លើម្ហូបអាហារ ។

នៅខែវិច្ឆិកា ឆ្នាំ២០០៦ ប្រាក់ចំណូលរបស់អ្នកលក់បន្លែតូចតាច ធ្លាក់ចុះ ២៧% ពីកំរិត ៨៣៨៥រៀល នៅខែវិច្ឆិកា ២០០៥ មកត្រឹម ៦១២៥រៀល ។ ការធ្លាក់ចុះប្រាក់ចំណូលនេះ បណ្ដាលមកពីកំណើនចំនួនអ្នកលក់បន្លែតូចតាច ។ ជាលទ្ធផល អ្នកលក់តូចតាច ៦៣% គ្មានកន្លែងលក់ ។ អ្នកលក់បន្លែតូចតាចភាគច្រើន (៩៧%) ជាស្ត្រី ក្នុងនេះមាន ៤៥%

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

រៀបការហើយ ៣៣% នៅលីវ និង ២២% ជាស្ត្រីមេម៉ាយ ។ អ្នកលក់បន្លែតូចតាច ៦០% ជាអ្នកចំណាកស្រុកមកពីខេត្ត ដូចជាខេត្តកណ្តាល កំពង់ស្ពឺ ស្វាយរៀង ព្រៃវែង និងតាកែវ ។ ក្នុងចំណោមអ្នកមកពីខេត្ត មាន ៥៤% ជួលផ្ទះគេស្នាក់នៅ ២៥% ស្នាក់នៅជាមួយបងប្អូន និង ២១% ត្រលប់ទៅផ្ទះវិញ ។

ប្រាក់ចំណូលរបស់អ្នករើសអេតចាយ នៅខែវិច្ឆិកា ឆ្នាំ២០០៦ ធ្លាក់ចុះ ១៩% ធៀបនឹងពេលដូចគ្នាឆ្នាំមុន មកត្រឹម ៣៩០៣រៀល ដែលជាចំណូលទាបបំផុតចាប់តាំងពីឆ្នាំ២០០៤ ។ ការធ្លាក់ចុះថ្លៃអេតចាយ និងកំណើនចំនួនអ្នករើសអេតចាយ គឺជាមូលហេតុចំបងនាំអោយចំណូលធ្លាក់ចុះ ។ អ្នករើសអេតចាយ ចំណាយប្រហែល ២១០០រៀល ក្នុងមួយថ្ងៃលើម្ហូបអាហារ ។

នៅខែវិច្ឆិកា ឆ្នាំ២០០៦ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់កម្មករសំណង់មានជំនាញ និងគ្មានជំនាញ ធ្លាក់ចុះ ៩% និង ២១% ធៀបនឹងអំឡុងពេល ដូចគ្នាឆ្នាំ២០០៥ ។ ការធ្លាក់ចុះនេះ បណ្តាលជាសំខាន់ពីកំណើនចំនួនកម្មករ សំណង់មានជំនាញ និងគ្មានជំនាញ ។ ដោយភាគច្រើននៃកម្មករសំណង់មានជំនាញ (៩៥%) និងគ្មានជំនាញ (៩៧%) ជាអ្នករកចំណូលសំខាន់ប្រចាំគ្រួសារ ដូចនេះប្រាក់ចំណូលរបស់ពួកគេ មិនគ្រប់គ្រាន់សំរាប់ផ្គត់ផ្គង់គ្រួសារទាំងមូលឡើយ ។

ប្រាក់ចំណូលប្រចាំថ្ងៃជាមធ្យមរបស់កម្មករកាត់ដេរ កើន ៣% ធៀបនឹងអំឡុងពេលដូចគ្នាឆ្នាំ២០០៥ ដល់ ៩២៦៤រៀល ។ កម្មករកាត់ដេរ ៦១% រាយការណ៍ថា ប្រាក់ចំណូលរបស់ពួកគេ ប្រែប្រួលទៅតាមការងារថែមម៉ោង និងអវត្តមានមិនបានទៅធ្វើការ ។ តាមធម្មតា ពួកគេផ្ញើប្រាក់មួយចំនួនត្រលប់ទៅផ្ទះ ដើម្បីផ្គត់ផ្គង់គ្រួសារ ហើយសន្សំទុកបន្តិចបន្តួចប៉ុណ្ណោះសំរាប់អនាគតរបស់ខ្លួន ។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកស៊ីឈ្នួលធ្វើស្រែ កើន ១០% ធៀបនឹងអំឡុងពេលដូចគ្នាឆ្នាំមុន ដល់ ៤៦៥៣រៀល ។ ការងារអាចរកបាននៅទីក្រុង ដូចជា កម្មករកាត់ដេរ និងកម្មករសំណង់ បានលើកទឹកចិត្តដល់កម្មករនៅជនបទ ជាពិសេសយុវជន អោយធ្វើចំណាកស្រុកមកធ្វើការនៅទីក្រុង ។ ការធ្វើចំណាកស្រុកនេះ បាននាំអោយចំនួនអ្នកស៊ីឈ្នួលធ្វើស្រែថយចុះ ដូច្នេះហើយ ប្រាក់ចំណូលក៏កើនឡើង ។ អ្នកស៊ីឈ្នួលធ្វើស្រែ ៧២% មានដីកសិកម្មតិចជាង១ហិកតា ហើយ ២៨% គ្មានដីទាល់តែសោះ ។ លើសពីនេះ អ្នកស៊ីឈ្នួលធ្វើស្រែ ៤៣% ជំពាក់បំណុលគេ ។ អ្នកខ្លះ បានខ្ចីប្រាក់ពីអ្នកចងការប្រាក់ ដែលកាន់កាប់ដីស្រែធំៗ ហើយសងវិញជាការលក់កំលាំងពលកម្ម រីឯអ្នកខ្លះទៀត ខ្ចីប្រាក់ពីអ្នកចងការប្រាក់ក្នុងអត្រាការប្រាក់ខ្ពស់ ហើយអ្នកផ្សេងទៀត ខ្ចីប្រាក់ពីអង្គការមិនមែនរដ្ឋាភិបាល ។


## Cambodia Development Review—2007 Subscription Rates

**Domestic Subscription (Individual)**

☐ English edition ($14) ☐ Khmer edition (5,000 riels) Payment by ☐ cash or ☐ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

☐ English edition ($60 for five copies) ☐ Khmer edition (20,000 riels for five copies) Payment by ☐ cash or ☐ local cheque (please add $2 to cover bank charges). Total payment enclosed..........

**International Subscription (Individual)**

☐ Thailand, Laos, Vietnam ☐ English edition ($25)* ☐ Khmer edition ($15)*
☐ Asia and Europe ☐ English edition ($30)* ☐ Khmer edition ($20)*
☐ Americas and Africa ☐ English edition ($35)* ☐ Khmer edition ($25)*

* Subscription includes postage. Payment by ☐ cash (in Phnom Penh) or ☐ cheque (please add $25 to cover bank charges for processing US dollar cheques). At present CDRI can accept payment from overseas only by US-dollar denominated cheque or bankers draft. Total payment enclosed..........

Title: ☐Mr ☐Ms ☐Dr ☐Other ..........

First name: .......... Last name: .......... Position: ..........

Organisation / Company: ..........

Address (CCC Box if applicable): ..........

City / Province: .......... Country: ..........

Telephone: .......... Fax: ..........

e-mail: .......... ☐ Tick to receive regular information about CDRI publications via e-mail

To subscribe simply fill in this form and return it to CDRI with your payment. Please make cheques payable to the Cambodia Development Resource Institute. Do not send cash through the post.
Please inform the Publications Section at CDRI if your contact details change.

## តារាង១. គំរោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ១៩៩៨-២០០៦

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 Q3 | Q4 | 2006 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 51.6 | 63.9 | 9.8 | 0.4 | 40.3 | 3.7 | 12.3 | 10.4 | 9.1 | 126.5 | 216.9 | 0.0 |
| ឧស្សាហកម្ម | 650.5 | 162.6 | 109.4 | 105.2 | 67.7 | 137.2 | 189.2 | 349.7 | 82.0 | 40.1 | 76.9 | 171.7 |
| កាត់ដេរ | *126.5* | *67.7* | *81.5* | *26.5* | *27.2* | *68.1* | *133.9* | *56.5* | *27.3* | *30.5* | *9.6* | *23.2* |
| សេវាកម្ម | 154.7 | 222.6 | 150.1 | 118.4 | 145.3 | 168.4 | 92.0 | 44.1 | 28.1 | 60.7 | 2,043.2 | 94.5 |
| សណ្ឋាគារ និងទេសចរណ៍ | *112.0* | *171.8* | *79.8* | *73.8* | *47.1* | *124.1* | *55.9* | *33.6* | *22.6* | *0.0* | *26.2* | *3.5* |
| សរុប | 856.8 | 449.1 | 269.2 | 224.0 | 253.3 | 309.3 | 293.5 | 404.2 | 119.2 | 227.3 | 2,337.0 | 266.2 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | 320.6 | -70.5 | 90.7 | 928.1 | -88.6 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 15.0 | -47.6 | -40.0 | -19.5 | 10.5 | 31.1 | -12.4 | 392.9 | 628.1 | -52.2 | 2331.2 | -34.1 |

*Including expansion project approvals. Up to June 2006. Source: Cambodian Investment Board*

## តារាង២. តំលៃគំរោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ១៩៩៨-២០០៦

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 Q3 | Q4 | 2006 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ, ផ្ទះ | 21.2 | 20.0 | 16.4 | 15.9 | 23.4 | 20.0 | 30.3 | 19.2 | 5.4 | 10.1 | 5.7 | 7.6 |
| ផ្ទះល្វែង | 227.3 | 290.5 | 174.8 | 167.8 | 179.9 | 91.6 | 167.6 | 41.3 | 45.1 | 39.9 | 51.8 | 67.1 |
| ផ្សេងៗ | 27.0 | 16.4 | 14.2 | 12.6 | 16.6 | 87.3 | 65.6 | 16.0 | 21.3 | 17.4 | 24.7 | 20.8 |
| សរុប | 275.4 | 326.8 | 205.4 | 196.2 | 219.8 | 198.9 | 263.4 | 76.5 | 71.8 | 67.4 | 82.2 | 95.5 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | -26.7 | -6.1 | -6.2 | 22.2 | 16.1 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 6.9 | 18.7 | -37.2 | -4.5 | 12.0 | -9.5 | 32.5 | -1.8 | 12.0 | -36.5 | -21.2 | 24.8 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង៣. ការនាំចេញ និងនាំចូល ឆ្នាំ១៩៩៨-២០០៦

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 Q3 | Q4 | 2006 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 784.4 | 941.1 | 1056.2 | 1268.2 | 1453.2 | 1708.1 | 2108.1 | 730.0 | 644.8 | 603.2 | 652.5 | 807.5 |
| រួមមាន: សំលៀកបំពាក់ | 378.0 | 554.0 | 962.1 | 1202.2 | 1355.8 | 1628.4 | 2027.0 | 709.8 | 601.0 | 568.5 | 632.4 | 782.0 |
| - ទៅសហរដ្ឋអាមេរិក | 74.1 | 486.0 | 714.1 | 840.9 | 943.4 | 1099.8 | 1270.9 | *489.5* | *408.1* | *402.5* | *438.6* | *522.8* |
| - ទៅសហភាពអឺរ៉ុប | - | - | 228.1 | 323.3 | 356.3 | 414.7 | 590.8 | *162.5* | *145.3* | *110.6* | *142.2* | *188.1* |
| - ប្រទេសផ្សេងទៀត | 82.0 | 68.0 | 19.9 | 38.0 | 56.1 | 113.8 | 165.3 | *57.8* | *47.5* | *55.3* | *51.6* | *71.0* |
| កសិកម្ម | - | - | 94.2 | 66.0 | 97.3 | 79.7 | 81.2 | 20.2 | 43.8 | 34.7 | 20.2 | 25.5 |
| - កៅស៊ូ | - | - | 29.6 | 25.9 | 29.7 | 35.1 | 38.3 | *9.8* | 13.4 | 7.8 | 9.8 | 13.6 |
| - ឈើ | - | - | 32.9 | 22.3 | 16.0 | 10.2 | 11.1 | *2.1* | 2.0 | 2.1 | 2.3 | 2.5 |
| - ត្រី | - | - | 5.4 | 6.0 | 4.3 | 2.8 | 10.6 | *0.8* | 6.6 | 1.9 | 1.0 | 1.6 |
| - ផ្សេងៗ | - | - | 26.2 | 11.8 | 47.4 | 31.6 | 21.3 | *7.5* | 21.9 | 22.9 | 7.0 | 7.7 |
| ការនាំចូលសរុប | 1112.2 | 1237.4 | 1417.7 | 1501.4 | 1707.8* | 1824.9 | 2149.0 | 632.3 | 691.1 | 690.7 | 774.9 | 784.3 |
| រួមមាន: - សាំង | - | - | - | - | 25.9 | 33.2 | 30.2 | 9.9 | 10.7 | 10.9 | 12.4 | 13.1 |
| - ម៉ាស៊ីន | - | - | - | - | 100.8 | 109.6 | 109.4 | 24.6 | 21.1 | 32.5 | 32.2 | 30.1 |
| - សំភារៈសំណង់ | - | - | - | - | 12.9 | 80.8 | 95.3 | 38.7 | 26.2 | 37.0 | 39.1 | 42.5 |
| - ផ្សេងៗ | - | - | - | - | 1568.2 | 1601.3 | 1914.0 | 559.1 | 633.1 | 610.3 | 691.2 | 698.5 |
| ជញ្ជីងពាណិជ្ជកម្ម | -327.8 | -296.3 | -361.5 | -233.2 | -254.6 | -116.8 | -40.9 | 97.7 | -46.3 | -87.5 | -122.4 | 23.2 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | - | - | - | 42.6 | -15.3 | -5.4 | 11.2 | 23.7 |
| ការនាំចេញសរុប | - | - | - | - | - | - | - | 41.7 | -11.7 | -6.4 | 8.2 | 23.7 |
| ការនាំចូលសរុប | - | - | - | - | - | - | - | -5.1 | 9.3 | -0.03 | 12.2 | 1.2 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 66.4 | 47.0 | 74.0 | 24.9 | 12.8 | 20.1 | 24.5 | 10.3 | 15.5 | 27.8 | 27.1 | 10.2 |
| ការនាំចេញសរុប | 59.0 | 20.0 | 12.2 | 20.1 | 14.6 | 17.5 | 23.4 | 9.2 | 18.3 | 30.3 | 26.7 | 10.6 |
| ការនាំចូលសរុប | 1.6 | 11.3 | 14.6 | 5.9 | 13.7 | 6.9 | 17.8 | 20.5 | 26.1 | 32.6 | 15.6 | 24.3 |

*Import data include tax-exempt imports. Sources: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF.*

## តារាង៤. ចំនួនភ្ញៀវបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ១៩៩៨-២០០៦

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 Q3 | Q4 | 2006 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ភ្ញៀវពាន់នាក់ | | | | | | | | | | | |
| តាមផ្លូវអាកាស | 186.3 | 262.9 | 351.7 | 408.4 | 523.0 | 456.0 | 626.1 | 202.8 | 251.5 | 275.4 | 204.4 | 224.2 |
| តាមផ្លូវគោក និងទឹក | 100.2 | 104.8 | 114.7 | 196.5 | 263.5 | 245.0 | 428.9 | 120.4 | 164.5 | 181.9 | 153.6 | 146.4 |
| សរុប | 286.5 | 367.7 | 466.4 | 604.9 | 786.5 | 701.1 | 1055.0 | 323.2 | 416.0 | 457.3 | 358.0 | 370.6 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | 10.0 | 28.7 | 9.9 | -21.7 | 4.1 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 30.9 | 28.3 | 26.8 | 29.7 | 30.0 | -10.9 | 50.5 | 41.8 | 9.8 | 20.2 | 21.2 | 14.7 |

*Source: Ministry of Tourism*

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ១៩៩៨-២០០៦ (ពាន់លានរៀល)

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 Q3 | 2005 Q4 | 2006 Q1* | 2006 Q2* | 2006 Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូលសរុប | 920 | 1326 | 1528 | 1529 | 1744 | 1765 | 2127 | 624.1 | 827.9 | 595.9 | 731.5 | 732.2 |
| ចំណូលចរន្ត | - | - | - | 1521 | 1728 | 1733 | 2107 | 609.5 | 701.6 | 593.2 | 726.9 | 716.8 |
| ចំណូលពន្ធ | 676 | 956 | 1096 | 1096 | 1227 | 1220 | 1577 | 436.2 | 553.8 | 484.7 | 558.6 | 565.8 |
| ពន្ធគយ | 376 | 432 | 376 | 376 | 424 | 395 | 513 | 123.7 | 189.8 | 135.5 | 151.7 | 157.2 |
| ចំណូលមិនមែនពន្ធ | 204 | 348 | 424 | 424 | 501 | 513 | 530 | 173.2 | 147.8 | 108.5 | 168.3 | 151.0 |
| អាជីវកម្មព្រៃឈើ | 20 | 36 | 28 | 29 | 15 | 7 | 2 | 0.3 | 0.1 | 0.5 | 0.7 | 0.3 |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | 88 | 108 | 124 | 122 | 123 | 120 | 94 | 30.9 | 38.0 | 11.4 | 30.0 | 11.7 |
| ចំណូលជាមូលធន | 36 | 12 | 8 | 9 | 16 | 31 | 19 | 14.6 | 126.3 | 2.7 | 4.6 | 15.4 |
| ចំណាយសរុប | 1296 | 1792 | 2332 | 2332 | 2948 | 2757 | 2932 | 912.4 | 998.9 | 881.7 | 1,012.0 | 924.0 |
| ចំណាយជាមូលធន | 368 | 624 | 976 | 977 | 1388 | 1171 | 1163 | 335.4 | 350.3 | 340.1 | 386.6 | 317.2 |
| ចំណាយចរន្ត | 980 | 1164 | 1356 | 1355 | 1560 | 1586 | 1769 | 577.0 | 648.6 | 541.7 | 625.4 | 606.9 |
| អប់រំ និងសុខាភិបាល | 132 | 280 | 344 | 343 | 454 | 473 | 518 | 202.1 | 228.4 | 80.3 | 202.3 | 150.1 |
| ការពារជាតិ និងសន្តិសុខ | 448 | 464 | 404 | 405 | 438 | 411 | 423 | 116.7 | 71.4 | 78.1 | 116.7 | 155.3 |
| ក្រសួងផ្សេងៗទៀត | 332 | 412 | 636 | 637 | 668 | 702 | 828 | 258.2 | 348.8 | 383.2 | 306.4 | 301.5 |
| ឱនភាពជាទូទៅ | -380 | -476 | -804 | -803 | -1204 | -992 | -805 | -288.3 | -171.0 | -285.9 | -280.5 | -191.9 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 268 | 416 | 768 | 766 | 1249 | 886 | 864 | 335.8 | 269.0 | 257.6 | 333.3 | 228.6 |
| ហិរញ្ញប្បទានក្នុងស្រុក | 112 | 60 | 36 | 37 | -45 | 106 | 148 | -47.5 | -97.9 | 28.3 | -52.8 | -36.7 |

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួល) អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ឆ្នាំ១៩៩៨-២០០៥

| | 1998 | 1999 | 2000 | 2001* | 2002 | 2003 | 2004 | 2005 Q3 | 2005 Q4 | 2006 Q1 | 2006 Q2 | 2006 Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ខេត្ត | - | 5.8 | 5.4 | -0.1 | 0.9 | 4.4 | 14.4 | 14.5 | 16.6 | 15.8 | 12.0 | |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | 14.8 | 4.0 | -0.8 | 0.2 | 3.3 | 1.1 | 3.9 | 4.6 | 6.6 | 6.1 | 4.5 | 4.9 |
| - ម្ហូបអាហារ | 14.1 | 7.6 | -3.4 | -2.5 | 1.8 | 1.5 | 6.4 | 6.0 | 10.6 | 10.6 | 6.3 | 5.8 |
| - ដឹកជញ្ជូន | 15.1 | 3.5 | 6.6 | -4.2 | 0.3 | 4.9 | 9.7 | 11.9 | 10.2 | 9.7 | 10.0 | 10.1 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ* | - | - | 3840.8 | 3916.3 | 3912.1 | 3973.3 | 4016.3 | 4,134.3 | 4,154.3 | 4,094.8 | 4106.6 | 4145.3 |
| រៀលក្នុង ១ បាតថៃ* | - | - | 95.8 | 88.2 | 91.1 | 95.8 | 99.9 | 100.2 | 101.4 | 103.5 | 108.0 | 110.3 |
| រៀលក្នុង ១០០ ដុងវៀតណាម* | - | - | 27.1 | 26.6 | 25.6 | 25.6 | 25.5 | 25.9 | 26.1 | 25.4 | 25.0 | 24.9 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 40.4 | 36.0 | 33.3 | 32.8 | 36.8 | 41.4 | 46.3 | 55.4 | 57.0 | 64.2 | 72.2 | 73.0 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 883 | 1065 | 1105 | 1329 | 1521 | 1508 | 3442 | 2,767 | 2,921 | 2,867 | 3,110 | 3,333 |
| ថ្លៃសាំង (រៀល/លីត្រ) | 1378 | 1613 | 1760 | 2113 | 2084 | 2150 | 2633 | 3,633 | 3,750 | 3,767 | 4,000 | 4,200 |

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ១៩៩៨-២០០៦ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 Q3 | 2005 Q4 | 2006 Q1 | 2006 Q2 | 2006 Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 1726 | 2019 | 2589 | 3080 | 3737 | 4027 | 4797 | 5,391 | 5,475 | 6,410 | 6,682 | 6,958 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -496 | -576 | -759 | -876 | -849 | -698 | -467 | -397 | -450 | -699 | -637 | -497 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | 178 | 103 | 3 | -75 | -119 | -128 | -209 | -404 | -421 | -755 | -831 | -892 |
| ឥណទានចំពោះផ្នែកឯកជន | 655 | 763 | 898 | 936 | 1059 | 1337 | 1817 | 2,386 | 2,394 | 2,778 | 2,997 | 3,288 |
| រូបិយវត្ថុទូទៅ M2 | 1230 | 1443 | 1831 | 2204 | 2888 | 3328 | 4329 | 4,994 | 5,025 | 5,711 | 6,045 | 6,461 |
| រូបិយវត្ថុ M1 | 543 | 531 | 540 | 609 | 813 | 937 | 1153 | 1,279 | 1,323 | 1,449 | 1,512 | 1,563 |
| រូបិយវត្ថុផ្សេងៗ | 687 | 911 | 1291 | 1594 | 2075 | 2391 | 3176 | 3,715 | 3,702 | 4,262 | 4,533 | 4,898 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 15.7 | 17.3 | 26.9 | 20.4 | 31.0 | 15.2 | 30.0 | 19.8 | 16.1 | 27.0 | 30.6 | 29.4 |
| រូបិយវត្ថុ M1 | 41 | -2.2 | 1.7 | 12.8 | 33.5 | 15.3 | 23.0 | 18.6 | 14.7 | 20.9 | 24.4 | 22.2 |
| រូបិយវត្ថុផ្សេងៗ | 1.3 | 32.6 | 41.7 | 23.5 | 30.2 | 15.2 | 32.8 | 20.2 | 16.6 | 33.6 | 32.8 | 31.9 |

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2000 វិច្ឆិកា | 2002 | 2003 | 2004 | 2005 វិច្ឆិកា | 2006 កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | 2006 ឧសភា | សីហា | វិច្ឆិកា |
| អ្នកធាក់ស៊ីក្លូ | 7594 | 8975 | 8572 | 7614 | 7768 | 7873 | 8546 | 6063 | 7393 | 11% | -23% | -5% |
| អ្នកលីសែង | 6233 | 7044 | 6676 | 6895 | 6473 | 6519 | 7375 | 5238 | 7045 | 5% | -13% | 9% |
| អ្នកលក់បន្លែតូចតាច | 5256 | 6566 | 6532 | 6947 | 8385 | 6186 | 6492 | 5197 | 6125 | -24% | -12% | -27% |
| អ្នករើសអេតចាយ | 2718 | 3685 | 3944 | 4446 | 4801 | 4984 | 4512 | 4266 | 3903 | -14% | -2% | -19% |
| អ្នកបំរើតាមភោជនីយដ្ឋាន* | 2111 | 4365 | 4932 | 4448 | 3893 | 4670 | 4243 | 4292 | 4498 | -1% | -8% | 16% |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 4198 | 4304 | 4177 | 4139 | 4224 | 4127 | 4541 | 4137 | 4653 | 19% | 3% | 10% |
| កម្មកររោងចក្រកាត់ដេរ | 6701 | 8904 | 9577 | 9277 | 8659 | 9184 | 7860 | 9264 | 8957 | 9% | 6% | 3% |
| អ្នករត់ម៉ូតូឌុប | 8,610 | 12,184 | 10,092 | 9204 | 9645 | 8884 | 8790 | 6744 | 8386 | -23% | -28% | -13% |
| កម្មករសំណង់គ្មានជំនាញ | 5399 | 6453 | 6558 | 6382 | 6691 | 5974 | 6407 | 6028 | 5263 | -21% | -1% | -21% |
| កម្មករសំណង់មានជំនាញ | 13,127 | 12,605 | 13,111 | 12,679 | 11,253 | 11,750 | 9833 | 9466 | 10215 | -20% | -8% | -9% |

*សំគាល់: ចំណូលអ្នកបំរើតាមភោជនីយដ្ឋាន អ្នកស៊ីឈ្នួលធ្វើស្រែ កម្មករកាត់ដេរ អ្នករត់ម៉ូតូឌុប និងកម្មករសំណង់មាននិងគ្មានជំនាញ ចាប់ធ្វើអង្កេតពីខែកុម្ភៈ ២០០០ ។ *ចំណូលអ្នកបំរើតាមហាងមិនរាប់បញ្ចូលអាហារ និងការស្នាក់នៅដែលម្ចាស់ភោជនីយដ្ឋានផ្តល់ឱ្យទេ ។ ប្រភព: តារាង៥: ទិន្នន័យបណ្តោះអាសន្នឆ្នាំ ២០០៦ *លេខកែតំរូវ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ / តារាង៦: * លេខកែតំរូវ CDRI, IMF, NIS, ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/ តារាង៧: NBC / តារាង៨: CDRI ។*

## តពីទំព័រ ២០ ព័ត៌មានថ្មីៗ ...

នៅខែកុម្ភៈ ឆ្នាំ២០០៧ CDRI-វិបសអ និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) បានចុះកិច្ចព្រមព្រៀងពង្រីកការចូលរួមវិភាគទានដ៏មានតំលៃរបស់ស៊ីដា ចំពោះចំណាយប្រតិបត្តិការស្នូលរបស់ CDRI-វិបសអ និងការគាំទ្រដល់កម្មវិធីស្រាវជ្រាវខាងគោលនយោបាយអភិបាលកិច្ចប្រជាធិបតេយ្យ និងកំណែទំរង់វិស័យសាធារណៈរបស់ CDRI-វិបសអ ។ ការគាំទ្ររបស់ស៊ីដា ជួយឱ្យ CDRI-វិបសអ អាចអនុវត្តការស្រាវជ្រាវពាក់ព័ន្ធនឹង គោលនយោបាយជំរុញដោយតំរូវការក្នុងស្រុកលើបញ្ហាអភិបាលកិច្ច អាចទទួលបានធនធានសំរាប់ការអភិវឌ្ឍន៍សមត្ថភាពបុគ្គលិកស្រាវជ្រាវរបស់ CDRI-វិបសអ ដូចជា ការសិក្សាថ្នាក់ក្រោយឧត្តម និងអាចផ្តល់សេវាពាក់ព័ន្ធ ដូចជា បណ្ណាល័យ ការបោះពុម្ពនិងផ្សព្វផ្សាយ ដែលមិនបានទទួលមូលនិធិពីគំរោងឯទៀតៗ ។ ភាពជាដៃគូរវាង CDRI-Sida គឺជាគំរូមួយដ៏ល្អសំរាប់ ការស្រាវជ្រាវខាងគោលនយោបាយ និងការអភិវឌ្ឍន៍ស្ថាប័នមានប្រសិទ្ធភាពខ្ពស់នៅកម្ពុជា ។

### ការស្រាវជ្រាវ

វិបសអ-CDRI បានផ្តួចផ្តើមធ្វើគំរោងថ្មីៗជាច្រើនទៀត នៅត្រីមាសទី១ ឆ្នាំ២០០៧ ។ គំរោងមួយស្រាវជ្រាវពីចំណាកស្រុករបស់យុវជនពីជនបទទៅទីក្រុង និងផលប៉ះពាល់ទៅលើនគរូបនីយកម្ម និងភាពក្រីក្រនៅកម្ពុជា ។ ការស្រាវជ្រាវនឹងធ្វើឡើងនៅក្រុងភ្នំពេញ ខេត្តបាត់ដំបង ទីប្រជុំជនប៉ោយប៉ែត និងខេត្តសៀមរាប ។ ការសិក្សានេះទទួលជំនួយទ្រទ្រង់ពីមូលនិធិសហប្រជាជាតិសំរាប់ប្រជាជន (UNFPA) ។ គំរោងមួយទៀតធ្វើការវាយតំលៃពីផលប៉ះពាល់នៃសេរីភាវូបនីយកម្មកសិកម្មទៅលើអ្នកដាំបន្លែនៅកម្ពុជា ។ គំរោងខ្នាតតូចនេះ នឹងពិនិត្យមើលថា តើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន (AFTA) បានប៉ះពាល់យ៉ាងណា ដល់ការរស់នៅនិងជីវភាពរបស់កសិករ ហើយតើអ្នកដាំបន្លែបានដោះស្រាយបញ្ហាប្រឈមខាងពាណិជ្ជកម្មនេះតាមរបៀបណា ។ គំរោងទទួលបានការគាំទ្រពីបណ្តាញស្រាវជ្រាវនិងបណ្តុះបណ្តាលខាងពាណិជ្ជកម្មនៅអាស៊ី-ប៉ាស៊ីហ្វិក (ARTNet) ។ គំរោងទី៣ ជាប់ទាក់ទងនឹងចំណាកស្រុកឆ្លងដែននៅមហាអនុតំបន់មេគង្គ (GMS) អនុវត្តដោយបណ្តាញវិភាគអភិវឌ្ឍន៍ (DAN) ដែលក្នុងនេះ វិបសអ-CDRI ជាស្ថាប័ននាំមុខគេ ។ តាមរយៈកិច្ចសហការរវាងស្ថាប័នស្រាវជ្រាវនៅកម្ពុជា ឡាវ ថៃ និងវៀតណាម ការសិក្សានឹងពិនិត្យពីនិន្នាការថ្មីៗនៃចំណាកស្រុកក្នុងតំបន់ ព្រមទាំងផលប៉ះពាល់នៃការផ្ញើប្រាក់មកផ្ទះរបស់អ្នកចំណាកស្រុក ទៅលើ

---

## តពីទំព័រ ១១ ការវិភាគផលប៉ះពាល់...

**តារាង ៨: ផលប៉ះពាល់សេដ្ឋកិច្ចប៉ាន់ស្មាននៃប្រាក់កំរៃនៅតាមព្រំដែននៅកំរិតសរុប និងបុគ្គល**

| ភាគខាងលិចកម្ពុជា | ចំនួនសរុប (តោន) | ពោតនាំចេញ (តោន) | ប្រាក់កំរៃក្នុងមួយតោន | ប្រាក់កំរៃសរុប (ដុល្លារUS) | គ្រួសារផលិតពោតសរុប | ប្រាក់កំរៃក្នុងមួយកសិដ្ឋាន * (ដុល្លារUS) |
|---|---|---|---|---|---|---|
| បាត់ដំបង | 108,018 | 102,617 | 8.09 | 830,172 | 14,946 | 55.54 |
| ប៉ៃលិន | 66,606 | 63,276 | 4.47 | 282,842 | 9,471 | 29.86 |
| បន្ទាយមានជ័យ | 9,554 | 9,076 | 8.09 | 73,427 | 7,496 | 9.80 |
| **សរុប** | **184,178** | **174,969** | - | **1,186,442** | - | - |

*សំគាល់ :* ប្រាក់កំរៃក្នុងមួយកសិដ្ឋានអាស្រ័យលើទំហំដី និងទិន្នផលគ្រួសារនីមួយៗទទួលបាន*

**តារាង ៩: ផលប៉ះពាល់ប៉ាន់ស្មាននៃប្រាក់កំរៃនៅតាមព្រំដែនទៅលើប្រាក់ចំណូលសុទ្ធពីផលិតកម្មពោតសំរាប់លក់**

| ភាគខាងលិចកម្ពុជា | ប្រាក់ចំណូលសុទ្ធក្នុងមួយហិកតា (ដុល្លារ US) | ប្រាក់កំរៃនៅតាមព្រំដែនក្នុងមួយតោន (ដុល្លារ US) | ប្រាក់កំរៃនៅតាមព្រំដែនក្នុងមួយហិកតា (ដុល្លារ US) | កំណើន * (%) |
|---|---|---|---|---|
| ផលិតកម្មពោតនៅប៉ៃលិន | 35.64 | 4.47 | 15.65 | 43.9 |
| ផលិតកម្មពោតនៅបាត់ដំបង/បន្ទាយមានជ័យ | 35.64 | 8.09 | 28.32 | 79.45 |

*សំគាល់ :* កំណើនគិតជាភាគរយនៃប្រាក់ចំណូលសុទ្ធ បើសិនជាប្រាក់កំរៃនៅតាមព្រំដែនត្រូវបានលុបបំបាត់*

នៅភាគខាងលិចកម្ពុជា គេប៉ាន់ស្មានថាមានរហូតដល់ ១,១លានដុល្លារ នៅឆ្នាំ២០០៥ ដែល ៤៦% កើតមាននៅខាងដីកម្ពុជា និង ៥៤% នៅខាងដីថៃ ។ រីឯនៅកំរិតកសិដ្ឋាននីមួយៗវិញ ប្រាក់កំរៃមានផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងដល់ប្រាក់ចំណូលសុទ្ធរបស់អ្នកផលិតពោត ។ ប្រសិនបើប្រាក់កំរៃនៅតាមព្រំដែនត្រូវបានលុបបំបាត់ គេអាចប៉ាន់ស្មានថា ប្រាក់ចំណូលសុទ្ធក្នុងមួយហិកតារបស់អ្នកផលិតពោត អាចកើន ៤៤% នៅប៉ៃលិន និង ៨០% នៅបាត់ដំបង/បន្ទាយមានជ័យ ។

**កំណត់សំគាល់**

១. ផលិតផលបាននាំចេញដោយគ្មានលិខិតអនុញ្ញាតពីក្រសួងពាណិជ្ជកម្ម

២. ប្រាក់កំរៃ មិនត្រូវប្រមូលយកលើផលិតផលកសិកម្មទេ យោងតាម AISP

៣. ការពន្យល់លំអិតពីមុខងាររបស់ពាណិជ្ជករនីមួយៗមានចុះក្នុងឯកសារ Nou 2005

# ព័ត៌មានថ្មីៗ ពី CDRI-វបសអ

## ការគ្រប់គ្រង

នៅថ្ងៃទី២៣-២៤ ខែកុម្ភៈ ឆ្នាំ២០០៧ CDRI-វបសអ បានសហការជាមួយធនាគារ ANZ Royal រៀបចំធ្វើសន្និសីទចក្ខុវិស័យកម្ពុជាលើកដំបូង លើប្រធានបទ "ចក្ខុវិស័យកម្ពុជា: កាលានុវត្តភាព ដើម្បីកំណើន ការអភិវឌ្ឍន៍ និងវិបុលភាពរួម ដោយមាន សម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ថ្លែងសុន្ទរកថាបើកសន្និសីទ ។ សន្និសីទនេះមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំខាងរដ្ឋាភិបាល វិស័យឯកជន សហគមន៍ អ្នកស្រាវជ្រាវ អង្គការ សង្គមស៊ីវិល និងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ ប្រមាណជាង ២០០នាក់ ។ ប្រធានបទលើកយកមកពិភាក្សាមានដូចតទៅ:

- ទិដ្ឋភាពម៉ាក្រូ: សូចនាករសំខាន់ៗនៃកំនើន ការអភិវឌ្ឍន៍ និងវិបុលភាពរួម
- កម្ពុជាក្នុងចំនោមប្រទេសជិតខាងដែលមានកំនើន និងកាលានុវត្តភាព
- ការជំរុញសន្ទុះក្បាលម៉ាស៊ីនកំណើន និងអភិវឌ្ឍន៍: ហិរញ្ញវត្ថុ វិស័យឯកជន និងវិនិយោគផ្ទាល់ពីបរទេស
- ការចេញពីការពឹងផ្អែកលើជំនួយឆ្ពោះទៅកាន់វិបុលភាពរួម: ការគ្រប់គ្រងធនធានប្រេងកាត និងឧស្ម័នរបស់កម្ពុជា
- ការប្រយុទ្ធនឹងភាពក្រីក្រ: ដល់ពេលអនុវត្តសកម្មភាពចំគោលដៅ
- ទស្សនវិស័យ និងមាគ៌ាឆ្ពោះទៅមុខ

ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជាលេខបន្ទាប់ នឹងផ្ដោតលើបញ្ហា និងបទបង្ហាញសំខាន់ៗនៅក្នុងសន្និសីទចក្ខុវិស័យ និងទស្សនវិស័យរយៈពេលខ្លី-មធ្យម សំរាប់ការអភិវឌ្ឍន៍កម្ពុជា ។ បទបង្ហាញនៅក្នុងសន្និសីទចក្ខុវិស័យកម្ពុជាឆ្នាំ២០០៧ មានចុះនៅលើវេបសាយរបស់ CDRI-វបសអ : www.cdri.org.kh ។

### *ការតែងតាំងក្នុងមុខតំណែងជាន់ខ្ពស់*

CDRI-វបសអ មានសេចក្ដីរីករាយសូមប្រកាសផ្សាយពីការតែងតាំងសមាសភាពថ្មីពីររូបនៅក្នុងថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ។ បណ្ឌិត Hossain Jalilian នឹងចូលកាន់តំណែងជានាយកផ្នែកស្រាវជ្រាវ ចាប់ពីខែមេសា ឆ្នាំ២០០៧តទៅ ។ បណ្ឌិត Jalilian ជាសេដ្ឋកិច្ចវិទូខាងអភិវឌ្ឍន៍ មានសញ្ញាប័ត្របណ្ឌិតមកពីសាលាសេដ្ឋកិច្ចនៃទីក្រុងឡុង ហើយបច្ចុប្បន្នកំពុងបំរើការនៅចក្រភពអង់គ្លេស នៅសាកលវិទ្យាល័យ Bradford ដែលនៅទីនោះលោកធ្លាប់ធ្វើជាសាស្ត្រាចារ្យ ជាប្រធានវគ្គសិក្សា និងជាអ្នកសំរបសំរួលកម្មវិធីថ្នាក់បណ្ឌិតខាងការសិក្សាពីអភិវឌ្ឍន៍ ។ ព្រមគ្នានេះដែរ លោកក៏ធ្វើជាទីប្រឹក្សាខាងការធ្វើគំរោងអភិវឌ្ឍន៍ និងសេដ្ឋកិច្ច នៅប្រទេសម៉ាឡេស៊ី នីហ្សេរីយ៉ា ម៉ូហ្សំប៊ិក ចិន វៀតណាម និងតង់ហ្សានី ។ បណ្ឌិត Brett Ballard ដែលជានាយកផ្នែកស្រាវជ្រាវស្ដីទី នឹងទទួលមុខតំណែងទីប្រឹក្សាស្រាវជ្រាវជាន់ខ្ពស់ ។

លោក អ៊ឹង ស៊ានលី នឹងទទួលដំណែងជានាយកផ្នែកប្រតិបត្តិការ ចាប់ពីចុងខែមីនា ឆ្នាំ២០០៧ ។ លោកមានសញ្ញាប័ត្រខាងផ្នែកហិរញ្ញវត្ថុ និងគ្រប់គ្រង និងជាអ្នកគ្រប់គ្រងជាន់ខ្ពស់មានបទពិសោធន៍ច្រើន ដោយធ្លាប់ធ្វើការជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងជំងឺអេដស៍ កម្មវិធីអភិវឌ្ឍន៍សហ ប្រជាជាតិ (UNDP) មជ្ឈមណ្ឌលត្រីពិភពលោក និងស្ថានទូតសហភាពអឺរ៉ុប នៅកម្ពុជា ។ ការតែងតាំងនេះគឺជាជោគជ័យមួយក្នុងទិសដៅធ្វើ កម្ពុជាភាវូបនីយកម្ម ដែល CDRI-វបសអ មានផែនការជាយូរមកហើយ ចំពោះមុខតំណែងអ្នកគ្រប់គ្រងប្រតិបត្តិ ដែលលោក Ray Hossinger បាន លាលែង ដើម្បីទៅទទួលតួនាទីថ្មីនៅប្រទេសអាហ្វ្រិកខាងត្បូង ។ CDRI-វបសអ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលទ្ធផលការងារដ៏ប្រសើរ ដែលលោក Ray Hossinger បានជួយដល់ CDRI-វបសអ កម្មវិធីនានា ប្រព័ន្ធនិងអភិបាលកិច្ចក្នុងរយៈពេលជាង ៤ឆ្នាំ កន្លងមក និងសូមជូនពរឱ្យលោកទទួលបានជោគជ័យក្នុងមុខតំណែងថ្មី ។

## ការគាំទ្ររបស់ ស៊ីដា (Sida)

*តទៅទំព័រទី ១៩*

ទស្សនាវដ្ដី
អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១១ លេខ១ ខែមករា-មីនា ឆ្នាំ២០០៧

**វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
☞ ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, (៨៥៥-១២) ៨៦៧ ២៧៨
🖷 (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@camnet.com.kh / pubs@cdri.forum.org.kh, http://www.cdri.org.kh

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅក្នុងពេលដំណាលគ្នា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ផ្ដល់ជាវេទិកាមួយ សំរាប់ពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ *អត្ថបទតាមដានសេដ្ឋកិច្ច* ផ្ដល់ការវាយតំលៃឯករាជ្យស្ដីពីដំណើរវិវត្តន៍នៃសេដ្ឋកិច្ចកម្ពុជា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិត ត្រូវមានចុះហត្ថលេខាប្រត្យក្សភាព លេខទូរស័ព្ទ និងអាសយដ្ឋាន ។ អ្នកនិពន្ធ ត្រូវទាក់ទងមក CDRI-វបសអ មុននឹងផ្ដល់អត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសំរាប់ការបោះពុម្ព ។ CDRI-វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយពុំមានបញ្ជាក់ហេតុផល ។

គ្រឹះស្ថានផ្សាយ: វបសអ
គ្រប់គ្រងកែសំរួល: យូ សិទ្ធីរិទ្ធ
កែសំរួលផលិតកម្ម: អ៊ុំ ចាន់ថា
ជំនួយការកែសំរួល: យេន សុផានី និង គីម ចិត្រា
រោងពុម្ពជប៉ុន ភ្នំពេញ រូបភាពទំព័រមុខ: រូបភាព CDRI

រក្សាសិទ្ធិ ២០០៧ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។

ISSN 1560-7615 / ISBN 978-99950-52-06-5

ទំនួលខុសត្រូវលើគំនិត សត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។
ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ CDRI-វបសអ ទេ ។